ក្រសួងព័ត៌មាន
MINISTRY OF INFORMATION

# ផែនការកសាងនិងអភិវឌ្ឍន៍
# មូលធនមនុស្សក្នុងវិស័យព័ត៌មាននិងសោតទស្សន៍
# ឆ្នាំ២០២៥-២០២៨








ខែមករា ឆ្នាំ២០២៥



“

កម្ពុជាមិនអាចក្លាយជាប្រទេសអ្នកមានបានទេ ប្រសិនបើធនធានមនុស្ស ពុំមានចំណេះដឹងនិងសមត្ថភាពជំនាញ ពុំអាចប្រកួតប្រជែងនៅលើឆាក អន្តរជាតិ ពុំមានសុខភាពល្អគ្រប់គ្រាន់ និងពុំមានសមត្ថភាពចូលរួមកសាង មូលដ្ឋាននៃសង្គម សេដ្ឋកិច្ច និងឧស្សាហកម្មដែលផ្អែកលើចំណេះដឹង។ ដូច្នេះ មិនមែនជាការចៃដន្យឡើយ ដែលយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ បានកំណត់យកអាទិភាពគន្លឹះ៥ គឺ មនុស្ស ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យា ពោល គឺយកកត្តា «មនុស្ស» ជាអាទិភាពខ្ពស់បំផុត។

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**
**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

”



“

មូលធនមនុស្សប្រកបដោយគុណវុឌ្ឍិ និងទេពកោសល្យជាមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់ការអភិវឌ្ឍក្រសួងព័ត៌មាន ប្រកបដោយផលិតភាពនិងប្រសិទ្ធផល។ ក្នុងន័យនេះ ក្រសួងព័ត៌មានចាំបាច់ត្រូវមានផែនការច្បាស់លាស់ ក្នុងការជ្រើសរើស បណ្តុះបណ្តាល អភិវឌ្ឍ និងដឹកនាំ ដើម្បីពង្រឹងវិស័យព័ត៌មាន និងសោតទស្សន៍ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ឯកឧត្តម នេត្រ ភក្ត្រា រដ្ឋមន្ត្រីក្រសួងព័ត៌មាន**

”

# អារម្ភកថា

រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា បានផ្តោតការយកចិត្តទុកដាក់ខ្ពស់បំផុតលើកត្តា **មូលធនមនុស្ស** នៅក្នុងការអភិវឌ្ឍប្រទេសជាតិឆ្ពោះទៅកាន់ប្រទេសមានចំណូលខ្ពស់ ស្របតាមចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០។ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានថ្លែងថា *"កម្ពុជាមិនអាចក្លាយជាប្រទេសអ្នកមានបានទេ ប្រសិនបើធនធានមនុស្ស ពុំមានចំណេះដឹងនិងសមត្ថភាពជំនាញ ពុំអាចប្រកួតប្រជែងនៅលើឆាកអន្តរជាតិ ពុំមានសុខភាពល្អគ្រប់គ្រាន់ និងពុំមានសមត្ថភាពចូលរួមកសាងមូលដ្ឋាននៃសង្គម សេដ្ឋកិច្ច និង ឧស្សាហកម្ម ដែលផ្អែកលើចំណេះដឹង។ ដូច្នេះ មិនមែនជាការចៃដន្យឡើយ ដែលយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ បានកំណត់យកអាទិភាពគន្លឹះ៥ គឺ **មនុស្ស ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យា** ពោល គឺយកកត្តា **មនុស្ស** ជាអាទិភាពខ្ពស់បំផុត"*។

មូលធនមនុស្ស ដែលសំដៅលើធនធានមនុស្សប្រកបដោយសមត្ថភាព ទេពកោសល្យ គោរពវិជ្ជាជីវៈ និងភាពច្នៃប្រឌិត ជាកត្តាគន្លឹះ និងមានសក្តានុពលដែលគាំទ្រដល់គ្រប់ដំណើរការអភិវឌ្ឍន៍ ព្រោះថាស្ថាប័ននីមួយៗ មិនអាចដំណើរការបានប្រកបដោយគុណភាព ប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងផលិតភាពឡើយ ប្រសិនបើគ្មានធនធានមនុស្សដែលមានគុណវុឌ្ឍិខ្ពស់ និងកិច្ចខិតខំប្រឹងប្រែងអនុវត្តការងារដោយប្រកាន់ខ្ជាប់នូវក្រមសីលធម៌ និងវិជ្ជាជីវៈ។ ក្នុងន័យនេះ **ធនធានមនុស្ស** គឺជាកត្តាស្នូលនៃរាល់គោលនយោបាយ និងយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍប្រទេស។ ដូចនេះ ការអប់រំ និងបណ្តុះបណ្តាលមូលធនមនុស្ស ជាភាពចាំបាច់មិនអាចខ្វះបាន និងជាយុទ្ធសាស្ត្រវិនិយោគវែងឆ្ងាយរបស់រាជរដ្ឋាភិបាល ក៏ដូចជាក្រសួងព័ត៌មានក្នុងការបង្កើតនូវមូលដ្ឋានមូលធនមនុស្សប្រកបដោយសមត្ថភាពជំនាញ និងចំណេះដឹងដ៏មានសក្តានុពល។

ក្នុងគោលបំណងឈានទៅសម្រេចឱ្យបាននូវគោលដៅនេះ ក្រសួងព័ត៌មានបានដាក់ចេញនូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យព័ត៌មាន និងសោតទស្សន៍ ឆ្នាំ២០២៤-២០២៨ ដោយបានកំណត់ទិសដៅយុទ្ធសាស្ត្រចំនួន៥គឺ៖ **ទី១.** ការធ្វើទំនើបកម្មស្ថាប័ន និងការកសាងរដ្ឋបាលទំនើប **ទី២.** ការពង្រឹងបទដ្ឋានបច្ចេកទេស និងការទទួលខុសត្រូវវិជ្ជាជីវៈ **ទី៣.** ***ការអភិវឌ្ឍធនធានមនុស្ស និងបណ្តុះស្មារតីមនសិការវិជ្ជាជីវៈ*** **ទី៤.** ការរៀបចំប្រព័ន្ធ និងយន្តការគ្រប់គ្រងលំហាត់ព័ត៌មាននិងសន្តិសុខព័ត៌មាន និង**ទី៥.** ការបង្កើនភាពជាដៃគូប្រកបដោយបរិយាប័ន្ននិងស័ក្តិសិទ្ធភាព។

ដើម្បីអនុវត្តឱ្យមានប្រសិទ្ធភាពនូវទិសដៅយុទ្ធសាស្ត្រទី៣ ខាងលើ ក្រសួងព័ត៌មានបានរៀបចំនូវផែនការសកម្មភាពស្តីពីការកសាង និងអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យព័ត៌មាន និងសោតទស្សន៍ ឆ្នាំ២០២៥-២០២៨ ដែលមានវិសាលភាពសម្រាប់អនុវត្តចំពោះមន្ត្រីរាជការក្រសួងព័ត៌មាន ដោយផ្តោតលើការបណ្តុះបណ្តាលកម្រិតជំនាញវិជ្ជាជីវៈថ្នាក់បរិញ្ញាបត្រ និងបរិញ្ញាបត្រ

ជាន់ខ្ពស់ និងការបណ្តុះបណ្តាលជំនាញបច្ចេកទេសវិជ្ជាជីវៈ ដើម្បីអភិវឌ្ឍសមត្ថភាពមន្ត្រី។ ផែនការសកម្មភាពនេះ ជាផែនទីក្នុងការរៀបចំកសាងកម្លាំងធនធាន និងមូលធនមនុស្សដោយផ្តោតលើៈ

*ទី១.* ការកសាង និងអភិវឌ្ឍជំនាញវិជ្ជាជីវៈ (បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់...)

*ទី២.* កម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេសវិជ្ជាជីវៈ និងការគ្រប់គ្រង

*ទី៣.* ការបង្កើនសមត្ថភាពផ្នែកច្បាប់សម្រាប់ការគ្រប់គ្រងអង្គភាព និង

*ទី៤.* ការលើកកម្ពស់សមត្ថភាពការងារទំនាក់ទំនងសាធារណៈ និងកិច្ចសហប្រតិបត្តិការ។

ឯកសារ **ផែនការសកម្មភាពស្តីពីការកសាង និងអភិវឌ្ឍន៍មូលធនមនុស្សក្នុងវិស័យព័ត៌មាន និងសោតទស្សន៍ ឆ្នាំ២០២៥-២០២៨** ជាផែនទីចង្អុលបង្ហាញផ្លូវក្នុងការរៀបចំធនធានមនុស្សក្នុងក្រសួងព័ត៌មានប្រកបដោយសក្តានុពល តាមរយៈការចែករំលែកនិងផ្តល់នូវចំណេះដឹង ជំនាញបច្ចេកទេស និងការបណ្តុះស្មារតីមនសិការវិជ្ជាជីវៈដល់មន្ត្រីរាជការ ដើម្បីសហការចូលរួមចំណែកក្នុងការប្រែក្លាយក្រសួងព័ត៌មានជា **ស្ថាប័នទំនាក់ទំនងសាធារណៈរបស់រាជរដ្ឋាភិបាលប្រកបដោយបុរេសកម្ម សកម្ម អន្តរសកម្ម ប្រសិទ្ធភាព និងប្រសិទ្ធផល** ដើម្បីគ្រប់គ្រងលំហាព័ត៌មាន និងសហការធានាសន្តិសុខព័ត៌មាន និងបំពេញតួនាទីស្នូលនិងមុខងារគាំទ្ររបស់ក្រសួងឱ្យមានប្រសិទ្ធភាពខ្ពស់ ព្រមទាំងចូលរួមសកម្មភាពក្នុងដំណើរការកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលកម្ពុជា។

ក្រសួងព័ត៌មានជឿជាក់ថា នឹងទទួលបាននូវការលើកកម្ពស់ចំណេះដឹងលើផ្នែកជំនាញបច្ចេកទេសនិងការគ្រប់គ្រងវិជ្ជាជីវៈក្នុងវិស័យព័ត៌មាននិងសោតទស្សន៍ ការបង្កើនសមត្ថភាពផ្នែកច្បាប់សម្រាប់ការគ្រប់គ្រងអង្គភាព និងការលើកកម្ពស់សមត្ថភាពការងារទំនាក់ទំនងសាធារណៈនិងកិច្ចសហប្រតិបត្តិការសម្រាប់មន្ត្រីរាជការក្រសួងព័ត៌មាន និងមន្ទីរព័ត៌មានរាជធានី-ខេត្ត តាមរយៈការអនុវត្តរាល់សកម្មភាពនៃផែនការនេះ។ ក្រសួងព័ត៌មានសូមថ្លែងអំណរគុណចំពោះក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធនានា ដែលតែងតែផ្តល់នូវការគាំទ្រនាពេលកន្លងមក និងសូមស្វាគមន៍ចំពោះការរួមចំណែកជាបន្តក្នុងការកសាង និងអភិវឌ្ឍធនធានមនុស្សក្នុងវិស័យព័ត៌មាន និងសោតទស្សន៍ឱ្យកាន់តែមានគុណភាព និងប្រសិទ្ធភាព៕

ថ្ងៃចន្ទ ១៥កើត ខែបុស្ស ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៥

**រដ្ឋមន្ត្រី**

**នេត្រ ភក្ត្រា**

# មាតិកា


**១. សេចក្តីផ្តើម** .......... ១
១.១. គោលនយោបាយ .......... ១
១.២. ស្ថានភាព និងបញ្ហា .......... ២
១.៣. អាទិភាព .......... ៣
**២. យុទ្ធសាស្ត្រអភិវឌ្ឍន៍មូលធនមនុស្ស** .......... ៣
**៣. ផែនការសកម្មភាព** .......... ៥
៣.១. វិសាលភាពផែនការ .......... ៥
៣.២. សកម្មភាពអនុវត្តការងារ .......... ៥
**ក. ការកសាង និងអភិវឌ្ឍន៍ជំនាញវិជ្ជាជីវៈ** .......... ៥
ក.១. ក្របខណ្ឌជាតិ .......... ៥
ក.២. ក្របខណ្ឌអន្តរជាតិ .......... ៧
**ខ. កម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេសនិងការគ្រប់គ្រង** .......... ៧
ខ.១. កម្មវិធីបណ្តុះបណ្តាលភាពជាអ្នកដឹកនាំស្ថាប័ន .......... ៧
ខ.២. កម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេសកម្រិតមូលដ្ឋាន .......... ៨
ខ.៣. កម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេសកម្រិតមធ្យម .......... ៩
ខ.៤. កម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេសកម្រិតខ្ពស់ .......... ១០
**គ. ការបង្កើនសមត្ថភាពផ្នែកច្បាប់** .......... ១១
គ.១. ការលើកកម្ពស់ការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្ត .......... ១១
គ.២. ការគ្រប់គ្រងរដ្ឋបាលផ្ទៃក្នុង .......... ១២
**ឃ. ការលើកកម្ពស់សមត្ថភាពការងារទំនាក់ទំនងសាធារណៈ** .......... ១២
ឃ.១. ការគ្រប់គ្រងលំហព័ត៌មាន និងសន្តិសុខព័ត៌មាន .......... ១២
ឃ.២. សមត្ថភាពគ្រប់គ្រងព័ត៌មាន និងសាធារណមតិមូលដ្ឋាន .......... ១៣
ឃ.៣. ការលើកកម្ពស់ការទូតព័ត៌មាន .......... ១៣
ឃ.៤. សណ្តាប់ធ្នាប់នៃកិច្ចប្រជុំ និងព្រឹត្តិការណ៍ .......... ១៣
ឃ.៥. ការបង្កើនកិច្ចសហប្រតិបត្តិការ និងការគាំទ្រ .......... ១៣
**៤. តម្រូវការ និងប្រភពថវិកា** .......... ១៤
៤.១. តម្រូវការ .......... ១៤
៤.២. ប្រភពថវិកា .......... ១៤

**៥.	យន្តការអនុវត្ត និងការតាមដាននិងវាយតម្លៃ** ......................... ១៤
៥.១.	គណៈកម្មការតម្រង់ទិស និងក្រុមការងារបច្ចេកទេស ......................... ១៤
៥.២.	មណ្ឌលបណ្តុះបណ្តាល និងវិក្រឹត្យការវិជ្ជាជីវៈសារព័ត៌មាន .................. ១៥
៥.៣.	សូចនាករតាមដាន ...................................................................... ១៥
**៦.	សេចក្តីសន្និដ្ឋាន** .......................................................................... ១៦
**ឧបសម្ព័ន្ធ**	ផែនការសកម្មភាពសម្រាប់ការកសាងនិងអភិវឌ្ឍន៍មូលធនមនុស្ស ក្នុងព័ត៌មាន និងសោតទស្សន៍ ឆ្នាំ២០២៥

* * * * * * * * *

# ផែនការសកម្មភាព
## ស្តីពី
## ការកសាង និងអភិវឌ្ឍន៍មូលធនមនុស្ស
## ក្នុងវិស័យព័ត៌មាន និងសោតទស្សន៍ ឆ្នាំ២០២៥-២០២៨

* * * * * * * * *

## ១. សេចក្តីផ្តើម

មូលធនមនុស្សជាកត្តាដ៏សំខាន់ក្នុងការកំណត់នូវប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព នៃប្រតិបត្តិការស្ថាប័ន។ ការគ្រប់គ្រងធនធានមនុស្ស ជាតួនាទីចម្បងក្នុងការអភិវឌ្ឍសមត្ថភាពស្ថាប័ន ដើម្បីសម្រេចបាននូវគោលដៅរួម។ ក្នុងវិស័យព័ត៌មាន និងសោតទស្សន៍ មូលធនមនុស្សក្នុងវិស័យនេះ ជាចលករយ៉ាងសំខាន់ក្នុងកិច្ចសហការគ្រប់គ្រងលំហាព័ត៌មាន និងសន្តិសុខព័ត៌មាន ពោលគឺ ព័ត៌មានដែលសម្បូណ៌បែបនិងទាន់សភាពការណ៍ ប្រកបដោយគុណភាព និងមិនបង្កនូវអេរិភាពក្នុងសង្គមជាតិ។ ការយកចិត្តទុកដាក់លើការកសាង និងអភិវឌ្ឍមូលធនមនុស្សក្នុងវិស័យព័ត៌មាន និងសោតទស្សន៍ ជាភាពចាំបាច់ ក្នុងការលើកកម្ពស់នូវសណ្តាប់ធ្នាប់សារព័ត៌មាន និងការផ្សព្វផ្សាយ ប្រកបដោយគុណភាព និងសុវត្ថិភាព។

នៅប៉ុន្មានឆ្នាំចុងក្រោយនេះ វិស័យព័ត៌មាន និងសោតទស្សន៍នៅកម្ពុជាមានការវិវត្តគួរឱ្យកត់សម្គាល់ ជាពិសេសក្នុងដំណាក់កាលនៃការរីកចម្រើនផ្នែកបច្ចេកវិទ្យា (ឌីជីថល...) ដែលបាននាំមកនូវការចាប់ផ្តើមនៃប្រព័ន្ធផ្សព្វផ្សាយជំនាន់ទី៥ និងការរួមចំណែកពីបច្ចេកវិទ្យានៃបញ្ញាសិប្បនិមិត្តជាដើម។ ក្នុងដំណាក់កាលនៃបដិវត្តន៍ឧស្សាហកម្ម ៤.០ ដើម្បីជំរុញសមាហរណកម្មប្រព័ន្ធផ្សព្វផ្សាយ អាទិភាពការងារក្រសួងព័ត៌មានត្រូវប្រកាន់យកគឺ ការធ្វើបរិវត្តកម្មឌីជីថល ការផ្លាស់ប្តូរប្រព័ន្ធផ្សាយពីអាណាឡូកទៅឌីជីថល ស្របតាមការប្តេជ្ញាចិត្តរួមរបស់អាស៊ាន និងការរៀបចំបទដ្ឋានគតិយុត្ត និងបទដ្ឋានបច្ចេកទេសសម្រាប់លើកកម្ពស់ការផ្សព្វផ្សាយ ដែលអាទិភាពទាំងនេះចាំបាច់ពឹងផ្អែកទាំងស្រុងលើធនធានមនុស្ស ដែលប្រកបដោយសមត្ថភាព និងទេពកោសល្យខ្ពស់។

### ១.១. គោលនយោបាយ

អនុលោមតាមយុទ្ធសាស្ត្របញ្ចកោណ -ដំណាក់កាលទី១ និងផែនការអភិវឌ្ឍន៍ជាតិ (២០២៤-២០២៨) ការកសាងនិងអភិវឌ្ឍមូលធនមនុស្ស ជាអាទិភាព ដែលក្រសួងព័ត៌មានបានកំណត់ជាទិសដៅយុទ្ធសាស្ត្រក្នុងការពង្រឹងសមត្ថភាពវិជ្ជាជីវៈរបស់មន្ត្រី និងអ្នកប្រកបអាជីពក្នុងវិស័យព័ត៌មាន និងសោតទស្សន៍។ ការកសាងនិងអភិវឌ្ឍមូលធនមនុស្សនឹងត្រូវពង្រឹង តាមរយៈការជ្រើសរើស និងការធ្វើទំនើបកម្មការបណ្តុះបណ្តាលនិងវិក្រឹតការវិជ្ជាជីវៈសារព័ត៌មាន ដើម្បីបង្កើនសមត្ថភាពបច្ចេកទេស គុណភាពព័ត៌មាន និងការគោរពក្រមសីលធម៌និងវិជ្ជាជីវៈ។

ជារួម រាជរដ្ឋាភិបាលកម្ពុជាតែងតែយកចិត្តទុកដាក់លើគោលនយោបាយអភិវឌ្ឍន៍ធនធានមនុស្ស ដោយផ្អែកលើចក្ខុវិស័យសេដ្ឋកិច្ច-សង្គមរបស់ប្រទេស ដើម្បីរួមចំណែកលើកស្ទួយសក្តានុពលធនធានមនុស្សសម្រាប់ការអភិវឌ្ឍប្រទេស។ រាជរដ្ឋាភិបាល បានផ្តោតលើការបង្កើនសមត្ថភាពមនុស្ស គុណភាពអប់រំ ការបណ្តុះបណ្តាលបច្ចេកទេសនិងជំនាញ ក៏ដូចជាការអភិវឌ្ឍសុខភាព និងសុខុមាលភាពសង្គម។ បញ្ចកោណទី១ នៃយុទ្ធសាស្ត្របញ្ចកោណ -ដំណាក់កាលទី១ បានកំណត់ច្បាស់ពីការអភិវឌ្ឍមូលធនមនុស្ស ដោយផ្តោតលើ៖

- ការពង្រឹងគុណភាពវិស័យអប់រំ កីឡា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
- ការបណ្តុះបណ្តាលជំនាញបច្ចេកទេស
- ការលើកកម្ពស់សុខភាព និងសុខុមាលភាព
- ការពង្រឹងប្រព័ន្ធគាំពារសង្គម និងប្រព័ន្ធស្បៀង និង
- ការពង្រឹងភាពជាប្រជាពលរដ្ឋក្នុងសង្គម។

ឈរលើមូលដ្ឋាននេះ ក្រសួងព័ត៌មានចូលរួមអនុវត្តប្រកបដោយភាពសកម្ម និងទទួលខុសត្រូវលើការដ្ឋានកំណែទម្រង់នានារបស់រាជរដ្ឋាភិបាលកម្ពុជានៅក្នុងនីតិកាលទី៧ នៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០២៣-២០២៨ ដោយបានប្រមូលផ្តុំ និងពិនិត្យឡើងវិញនូវរាល់បញ្ហាចម្បងៗ ដើម្បីដាក់ចេញនូវទិសដៅយុទ្ធសាស្ត្រចំនួន៥គឺ៖ **ទី១.** ការធ្វើទំនើបកម្មស្ថាប័ននិងការកសាងរដ្ឋបាលទំនើប **ទី២.** ការពង្រឹងបទដ្ឋានបច្ចេកទេសនិងការទទួលខុសត្រូវវិជ្ជាជីវៈ **ទី៣.** ***ការអភិវឌ្ឍធនធានមនុស្សនិងបណ្តុះស្មារតីមនសិការវិជ្ជាជីវៈ*** **ទី៤.** ការរៀបចំប្រព័ន្ធនិងយន្តការគ្រប់គ្រងលំហព័ត៌មាននិងសន្តិសុខព័ត៌មាន និង**ទី៥.** ការបង្កើនភាពជាដៃគូប្រកបដោយបរិយាប័ន្ននិងស័ក្តិសិទ្ធភាព។

## ១.២. ស្ថានភាព និងបញ្ហា

ជារួម បញ្ហាប្រឈមដែលជះឥទ្ធិពលដល់ដំណើរការវិស័យព័ត៌មាន និងសោតទស្សន៍ត្រូវបានកំណត់ដូចមានក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យព័ត៌មាន និងសោតទស្សន៍ ឆ្នាំ២០២៤-២០២៨ ដែលក្នុងនោះរួមមាន៖

- បញ្ហាសន្តិសុខព័ត៌មាន ដែលផ្តោតលើការទទួលបានព័ត៌មាន គុណភាពព័ត៌មាន និងសុវត្ថិភាពព័ត៌មាន
- ការសាយភាយព័ត៌មានក្លែងក្លាយគ្មានព្រំដែន
- ការវិវឌ្ឍនៃសង្គម និងសេដ្ឋកិច្ច ក្នុងបរិបទឌីជីថល
- ឥទ្ធិពលនៃបញ្ញាសិប្បនិមិត្ត ដែលនឹងជ្រៀតចូលក្នុងវិស័យសារព័ត៌មាន
- អក្ខរកម្មឌីជីថល និងព័ត៌មាន
- ការអភិវឌ្ឍចំណេះដឹងសម្របតាមការរីកចម្រើនផ្នែកបច្ចេកវិទ្យា
- ការបំពានក្រមសីលធម៌វិជ្ជាជីវៈសារព័ត៌មាន និង

- ចំណេះដឹងមូលដ្ឋាន និងបទពិសោធការងារអន្តរជាតិរបស់អ្នកសារព័ត៌មានឯកជនមួយចំនួន នៅមានកម្រិត។

ទន្ទឹមនេះដែរ គ្រឹះស្ថានផ្តល់ការបណ្តុះបណ្តាលក្នុងវិស័យសារព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយសោតទស្សន៍នៅមានកម្រិត ដោយសារទីផ្សារការងារក្នុងវិស័យនេះនៅមានបញ្ហាលើការគ្រប់គ្រង ដែលទាមទារនូវការរៀបចំសណ្តាប់ធ្នាប់សមស្របតាមស្តង់ដារជាតិមួយ ក៏ដូចជាការអនុវត្តល្អនានាជាអន្តរជាតិ។ បញ្ហាដែលគួរកត់សម្គាល់ដែរ គឺកន្លងមកការបណ្តុះបណ្តាលមិនទាន់ឆ្លើយតបតាមតម្រូវការ ការងារមិនមានលក្ខណៈជាប្រព័ន្ធ មិនមានផែនការច្បាស់លាស់លើការបណ្តុះបណ្តាលធនធានមនុស្ស មិនមានយន្តការដាក់លាក់ក្នុងការវាយតម្លៃប្រសិទ្ធភាពការងារ និងការប្រើប្រាស់បច្ចេកវិទ្យានៅមានកម្រិត ជាដើម។

## ១.៣. អាទិភាព

យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ នៅតែចាត់ទុកមនុស្សជាអាទិភាពទី១ ក្នុងការអភិវឌ្ឍ ដូចដែលបញ្ចកោណទី១ បានកំណត់ច្បាស់ពីការអភិវឌ្ឍមូលធនមនុស្ស ដែលជាមូលដ្ឋានគ្រឹះដ៏សំខាន់សម្រាប់ជំរុញសន្ទុះនៃការអភិវឌ្ឍកម្ពុជា។ ក្នុងន័យនេះ រាជរដ្ឋាភិបាលបានសម្រេចទិសលើះ ***ទី១.*** ការពង្រឹងគុណភាពវិស័យអប់រំ កីឡា វិទ្យាសាស្ត្រ និង**បច្ចេកវិទ្យា** ***ទី២.*** ការបណ្តុះបណ្តាល**ជំនាញបច្ចេកទេស** ***ទី៣.*** ការលើកម្ពស់សុខភាពនិងសុខុមាលភាព ***ទី៤.*** ការពង្រឹងប្រព័ន្ធគាំពារសង្គម និងប្រព័ន្ធស្បៀង និងទី៥. ការពង្រឹង**ភាពជាពលរដ្ឋ**ក្នុងសង្គម។

ក្នុងន័យនេះ យុទ្ធសាស្ត្រទី៣ នៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យព័ត៌មាន និងសោតទស្សន៍ស្តីពីការអភិវឌ្ឍមូលធនមនុស្ស និងបណ្តុះស្មារតីមនសិការវិជ្ជាជីវៈ បានកំណត់ពីះ

***ទី១.*** ទិសដៅពង្រឹងសមត្ថភាពស្ថាប័ន គុណភាពមន្ត្រី និងប្រសិទ្ធភាពការងារ

***ទី២.*** ការលើកកម្ពស់ការគោរពវិន័យការងារ និងការទទួលខុសត្រូវឱ្យបានម៉ឺងម៉ាត់ ការពង្រឹងសមត្ថភាពចំណេះដឹង និងជំនាញឌីជីថលក្នុងវិស័យព័ត៌មាននិងប្រព័ន្ធផ្សព្វផ្សាយ និងការអនុវត្តកម្មវិធីបណ្តុះបណ្តាលជំនាញគ្រប់គ្រង និងភាពជាអ្នកដឹកនាំ និង

***ទី៣.*** ការលើកទឹកចិត្តតាមរយៈផលប្រយោជន៍ដែលត្រូវទទួល ដោយលុបបំបាត់ករណីទំនាស់ផលប្រយោជន៍ក្នុងស្ថាប័ន បង្កើនការយកចិត្តទុកដាក់លើសុខុមាលភាពមន្ត្រី បង្កើននវានុវត្តន៍ គុណភាពការងារ និងត្រូវប្រកាន់ខ្ជាប់នូវសេចក្តីថ្លៃថ្នូរ អនុវត្តការបែងចែកផលប្រយោជន៍មន្ត្រី និងការគិតគូរអំពីកម្មវិធីមនុស្សធម៌ជូនដល់មន្ត្រី។

# ២. យុទ្ធសាស្ត្រអភិវឌ្ឍន៍មូលធនមនុស្ស

ប្រមុខរាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៧ នៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជាបានប្រកាស

ធ្វើកំណែទម្រង់រដ្ឋបាលសាធារណៈ ក្រោមពាក្យស្លោក "**អ្នកចេះ គឺជាប់**" ពោលគឺការប្រកាន់យកនូវសមត្ថភាពជាមូលដ្ឋាន ព្រោះថាសមត្ថភាពជាកត្តាដែលមិនអាចខ្វះបាន។ ក្នុងន័យនេះ ការអភិវឌ្ឍធនធានមនុស្ស ជាអាទិភាពចម្បង។

ដូចបានកំណត់ក្នុងស្នូលនៃយុទ្ធសាស្ត្របញ្ចកោណ មុំទី២បានកំណត់ច្បាស់ពីគោលបំណងនៃការលើកកម្ពស់សមត្ថភាពធនធានមនុស្ស និងការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តការងារ ដើម្បីកសាងធនធានមនុស្សប្រកបដោយសមត្ថភាព ជំនាញ ឆន្ទៈម្ចាស់ការ និងក្រមសីលធម៌ ស្របតាមតួនាទីនិងការទទួលខុសត្រូវ។

បច្ចុប្បន្ន តាមស្ថិតិរបស់ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈនៃក្រសួងព័ត៌មាន មន្ត្រីរាជការសរុបរបស់ក្រសួងព័ត៌មានមានចំនួន២ ៧៨២នាក់ ក្នុងនោះថ្នាក់ដឹកនាំកម្រិតនយោបាយចំនួន៤៨៣រូប (រដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ទីប្រឹក្សា និងជំនួយការ) មន្ត្រីរាជការចំនួន១ ៦៣០រូប មន្ត្រីកិច្ចសន្យាចំនួន៧៨រូប និងមន្ត្រីផ្សេង៤៣៤រូប។ ជំរឿនកម្រិតវប្បធម៌លើមន្ត្រីរាជការបានបង្ហាញថា ក្រសួងព័ត៌មានមាន៖

១. ថ្នាក់បណ្ឌិត (ថ្នាក់ដឹកនាំ៩រូប និងមន្ត្រីរាជការ៧រូប)
២. បរិញ្ញាបត្រជាន់ខ្ពស់ (ថ្នាក់ដឹកនាំ ២២រូប និងមន្ត្រីរាជការ ១៦៩រូប)
៣. បរិញ្ញាបត្រ (ថ្នាក់ដឹកនាំ២៥រូប និងមន្ត្រីរាជការ៥១១រូប)
៤. បរិញ្ញាបត្ររង (មន្ត្រីរាជការ៥៥រូប)
៥. មធ្យមសិក្សាទុតិយភូមិ (ថ្នាក់ដឹកនាំ៦រូប និងមន្ត្រីរាជការ១៦២រូប) និង
៦. ក្រោមមធ្យមសិក្សាទុតិយភូមិ (ថ្នាក់ដឹកនាំ៣រូប និងមន្ត្រីរាជការ១៤៧រូប)។

ទន្ទឹមនេះ តាមរយៈស្ថិតិក្រសួងព័ត៌មាន មន្ត្រីរាជការថ្នាក់ជាតិ (ឋានៈចាប់ពីអគ្គនាយករងហូតដល់មន្ត្រី) ដែលនឹងត្រូវចូលនិវត្តន៍ក្នុងរយៈពេល១០ឆ្នាំ (គិតហូតដល់ឆ្នាំ២០៣៣) មានចំនួន៣៧០នាក់ ក្នុងនោះគិតត្រឹមឆ្នាំ២០២៨ មានចំនួន១៩៩នាក់ និងពីឆ្នាំ២០២៨-២០៣៣ មានចំនួន១៧១នាក់ បន្ថែមទៀត។ ដោយឡែក នៅថ្នាក់ក្រោមជាតិ ក្នុងរយៈពេល១០ឆ្នាំទៅមុខ មន្ត្រីរាជការដែលមានឋានៈពីប្រធានមន្ទីរដល់មន្ត្រីនឹងត្រូវចូលនិវត្តន៍សរុប១៥៧នាក់ ក្នុងនោះគិតត្រឹមឆ្នាំ២០២៨ មានចំនួន៨០នាក់ និងពីឆ្នាំ២០២៨-២០៣៣ មានចំនួន៧៧នាក់។ ជារួម ក្នុងរយៈពេល៥ឆ្នាំទៅមុខ ចំនួនមន្ត្រីរាជការក្រសួងព័ត៌មាន (ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ) ត្រូវចូលនិវត្តន៍ចំនួន២៧៩នាក់ និងគិតដល់ឆ្នាំ២០៣៣ មានចំនួនចូលនិវត្តន៍បន្ថែមចំនួន២៤៨នាក់។ ជាមួយចំនួននៃការចូលនិវត្តន៍នេះ ចាំបាច់ក្រសួងត្រូវមានផែនការសកម្មភាពក្នុងការកសាង និងអភិវឌ្ឍន៍មូលធនមនុស្សមួយសម្រាប់ការរៀបចំកម្លាំងបន្តវេនដ៏មានប្រសិទ្ធភាព។

ក្នុងគោលដៅពង្រឹង និងពង្រីកសមត្ថភាពជំនាញ ចំណេះដឹង ចំណេះធ្វើ បទពិសោធ សីលធម៌ និងមនសិការវិជ្ជាជីវៈ ព្រមទាំងការយល់ដឹងអំពីច្បាប់ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្ត

នានារបស់រាជរដ្ឋាភិបាល ក្រសួងព័ត៌មានបានកំណត់នូវយុទ្ធសាស្ត្រអភិវឌ្ឍមូលធនមនុស្សដើម្បីជំរុញការអភិវឌ្ឍសមត្ថភាពមន្ត្រីស្របតាមការវិវត្តនៃសង្គមនិងបច្ចេកវិទ្យា រៀបចំកម្លាំងបន្តវេនប្រកបដោយសក្តានុភាព និងរៀបចំផែនទីឯកភាពការងារក្នុងការរៀបចំកម្លាំងធនធាន ដូចខាងក្រោម៖

*ទី១.* ការកសាង និងអភិវឌ្ឍជំនាញវិជ្ជាជីវៈ (បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់...)

*ទី២.* កម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេសវិជ្ជាជីវៈ និងការគ្រប់គ្រង

*ទី៣.* ការបង្កើនសមត្ថភាពផ្នែកច្បាប់សម្រាប់ការគ្រប់គ្រងអង្គភាព

*ទី៤.* ការលើកកម្ពស់សមត្ថភាពការងារទំនាក់ទំនងសាធារណៈ និងកិច្ចសហប្រតិបត្តិការ។

## ៣. ផែនការសកម្មភាព

### ៣.១. វិសាលភាពផែនការ

ផែនការសកម្មភាពស្តីពីការកសាង និងអភិវឌ្ឍន៍មូលធនមនុស្សក្នុងវិស័យព័ត៌មាន និងសោតទស្សន៍ ឆ្នាំ២០២៥-២០២៨ មានវិសាលភាពសម្រាប់អនុវត្តចំពោះមន្ត្រីរាជការក្រសួងព័ត៌មានដោយផ្តោតលើការបណ្តុះបណ្តាលកម្រិតជំនាញវិជ្ជាជីវៈថ្នាក់បរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ និងការបណ្តុះបណ្តាលជំនាញបច្ចេកទេសដើម្បីអភិវឌ្ឍសមត្ថភាពមន្ត្រី។ សម្រាប់ឆ្នាំ២០២៥នេះ ក្រសួងព័ត៌មានបានផ្តោតលើសកម្មភាពបណ្តុះបណ្តាលដូចមានក្នុងចំណុច ៣.២ ខាងក្រោម។

### ៣.២. សកម្មភាពអនុវត្តការងារ

ផ្អែកលើយុទ្ធសាស្ត្រទាំង៤ ខាងលើ សកម្មភាពនៃការងារសម្រាប់១ឆ្នាំ (ឆ្នាំ២០២៥) ត្រូវបានកំណត់ដូចខាងក្រោម៖

#### ក. ការកសាង និងអភិវឌ្ឍន៍ជំនាញវិជ្ជាជីវៈ

ក្នុងការរៀបចំនូវកម្លាំងបន្តវេនប្រកបដោយសក្តានុពល ក្រសួងព័ត៌មានបានដាក់ចេញនូវទិសដៅរយៈពេលវែងចំពោះការកសាង និងអភិវឌ្ឍន៍ជំនាញវិជ្ជាជីវៈព័ត៌មាន និងសោតទស្សន៍ (កម្រិតបរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់) ដោយបានបង្កើតនូវកិច្ចសហប្រតិបត្តិការក្នុងភាពជាដៃគូជាមួយស្ថាប័នជាតិ និងអន្តរជាតិ។

#### ក.១. ក្របខណ្ឌជាតិ

**បណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា (ប.ប.ឌ.)**

ដើម្បីចូលរួមអនុវត្តក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថល កម្ពុជា ២០២១-២០៣៥ និងគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥ ក្រសួងព័ត៌មានយកចិត្តទុកដាក់លើការកសាងសមត្ថភាពឌីជីថល ក្នុងគោលបំណងអនុវត្តឱ្យបានជោគជ័យលើការធ្វើបរិវត្តកម្មឌីជីថលក្នុងវិស័យព័ត៌មាន និងសោតទស្សន៍។

ក្នុងន័យនេះ ក្រសួងបានជំរុញ និងបង្កើនកិច្ចសហការជាមួយបណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា (ប.ប.ឌ.) លើការបណ្តុះបណ្តាលជំនាញបរិញ្ញាបត្រឌីជីថល នៅវិទ្យាស្ថានបច្ចេកវិទ្យា

ឱដីថល ការស្នើសុំអាហារូបករណ៍ **ទេពកោសល្យឱដីថល តេជោ** សម្រាប់សិក្សាថ្នាក់បរិញ្ញាបត្រជំនាញបច្ចេកវិទ្យាឱដីថល និងជាពិសេសការការស្នើសុំវគ្គបណ្តុះបណ្តាលនៅវិទ្យាស្ថានអភិបាលកិច្ចឱដីថលលើចំណេះដឹងជំនាញផ្នែកឱដីថល (ជំនាញ ២ ចំណេះដឹង ១ កសាងមូលធនមនុស្សឱដីថល) និងកម្មវិធីភាពជាអ្នកដឹកនាំឱដីថល។

**សាលាភូមិន្ទរដ្ឋបាល**

ជាមួយនេះ ដើម្បីបង្កើតកិច្ចសហប្រតិបត្តិការ និងលើកកម្ពស់ការគាំទ្រពីគ្នាទៅវិញទៅមកពាក់ព័ន្ធនឹងការអភិវឌ្ឍសមត្ថភាព ការសិក្សាអប់រំ ការបណ្តុះបណ្តាល ការស្រាវជ្រាវ និងគម្រោងកម្មវិធីផ្សេងៗដោយផ្អែកលើគោលការណ៍ពិគ្រោះយោបល់ ឯកភាព សមភាព យុត្តិធម៌ និងការផ្តល់នូវអត្ថប្រយោជន៍ទៅវិញទៅមក ក្រសួងព័ត៌មាន និងសាលាភូមិន្ទរដ្ឋបាលបានចុះអនុស្សរណៈនៃការយោគយល់ ក្នុងគោលដៅបង្កើនសមត្ថភាពមន្ត្រីរាជការក្រសួងព័ត៌មាន តាមរយៈការកសាងចំណេះដឹង ជំនាញបន្ថែម និងលទ្ធភាពបំពេញការងារដើម្បីគុណផល និងត្រៀមខ្លួនបានកាន់តែល្អប្រសើរសម្រាប់ការវិវឌ្ឍថ្មីៗ នាពេលអនាគត។

ក្នុងន័យនេះ ក្រសួងព័ត៌មាននឹងស្នើសុំជូនមន្ត្រីរាជការសម្រាប់ការបណ្តុះបណ្តាលបន្តលើវគ្គវិក្រឹត្យការមន្ត្រីជាន់ខ្ពស់ វិក្រឹត្យការមន្ត្រីគ្រប់គ្រងរដ្ឋបាល វិក្រឹត្យការមន្ត្រីមធ្យម និងវិក្រឹត្យការមន្ត្រីក្រមការ តាមកម្មវិធីរបស់សាលាភូមិន្ទរដ្ឋបាល។

**សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ (ស.ភ.ព.អ)**

ទន្ទឹមនេះ អនុវត្តតាមស្មារតីនៃលិខិត១៨១១ សជណ.ពប របស់ទីស្តីការគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៤ ក្រសួងព័ត៌មានបានធ្វើកិច្ចសហប្រតិបត្តិការជាមួយសាកលវិទ្យាល័យភ្នំពេញអន្តរជាតិ (ស.ភ.ព.អ) លើកម្មវិធីបណ្តុះបណ្តាលធនធានមនុស្សសម្រាប់វិស័យព័ត៌មាន និងសោតទស្សន៍ ប្រកបដោយគុណវឌ្ឍិ លើកម្រិតបរិញ្ញាបត្រ បរិញ្ញាបត្ររង និងកម្រិតវិជ្ជាជីវៈ ក្នុងព្រះរាជាណាចក្រកម្ពុជា ដោយចាប់ផ្តើមពីឆ្នាំ២០២៥តទៅ។

តាមរយៈកិច្ចសហប្រតិបត្តិការនេះ ក្រសួងព័ត៌មាននឹងគាំទ្រលើកម្រិតបច្ចេកទេសនិងរដ្ឋបាល ផ្តល់ការណែនាំនិងសហការអភិវឌ្ឍកម្មវិធីសិក្សាគ្រប់ជំនាញបច្ចេកទេសតាមកម្រិតនីមួយៗក្នុងវិស័យសារព័ត៌មាន ផ្តល់បន្ទប់ពិសោធន៍និងកន្លែងបង្ហឹកនិស្សិតគ្រប់កម្រិតសិក្សាលើគ្រប់ជំនាញបច្ចេកទេសក្នុងវិស័យសារព័ត៌មាន និងផ្តល់អាទិភាពការងារដល់និស្សិតបញ្ចប់ការសិក្សា ដែលបានទទួលការបណ្តុះបណ្តាលដោយ ស.ភ.ព.អ។

ក្នុងន័យនេះ ក្រសួងព័ត៌មាននឹងចូលរួមស្វែងរកដៃគូសហប្រតិបត្តិការជាតិ និងអន្តរជាតិសម្រាប់គាំទ្រដល់ដំណើរការនៃកិច្ចសហប្រតិបត្តិការ ចូលរួមផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងផ្តល់ហត្ថលេខាលើសន្លឹកសញ្ញាបត្រគ្រប់កម្រិតសិក្សាលើគ្រប់ជំនាញ ដែលបានបណ្តុះបណ្តាល។

ទន្ទឹមនេះដែរ ក្រសួងនឹងសហការជាមួយ ស.ភ.ព.អ រៀបចំយន្តការសម្រាប់ដឹកនាំនិងគ្រប់គ្រងកិច្ចសហប្រតិបត្តិការ និងរៀបចំបច្ចេកទេសនិងមុខវិជ្ជាបង្រៀន ដើម្បីឱ្យដំណើរការកសាងគ្រឹះធនធានមនុស្សក្នុងវិស័យព័ត៌មាននិងសោតទស្សន៍ ប្រព្រឹត្តទៅប្រកបដោយគុណភាព និងស័ក្តិសិទ្ធភាព តាមរយៈកម្មវិធីកសាងនិងអភិវឌ្ឍសមត្ថភាពជំនាញគ្រប់គ្រងនិងដឹកនាំ និងជំនាញបច្ចេកទេសវិជ្ជាជីវៈដែលផ្តោតជាសំខាន់លើជំនាញទំនាក់ទំនងសាធារណៈ សារព័ត៌មាន ប្រព័ន្ធផ្សព្វផ្សាយឌីជីថល និងការគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយសោតទស្សន៍។

ស្របគ្នានេះដែរ ជាមួយការផ្តល់នូវការគាំទ្រដល់មន្ត្រីរាជការ និងមន្ត្រីកិច្ចសន្យា ដែលមានបំណងបន្តការសិក្សា ក្រសួងនឹងផ្តល់នូវការលើកទឹកចិត្តតាមរយៈការស្នើសុំផ្តល់អាហារូបករណ៍ ឬការបញ្ចុះតម្លៃលើការចុះឈ្មោះសិក្សានៅ ស.ភ.ព.អ ចំនួន៣០ភាគរយ និងដៃគូផ្សេងៗទៀត។

### ក.២. ក្របខណ្ឌអន្តរជាតិ

ក្នុងក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការទ្វេភាគី ជាមួយរដ្ឋជាសមាជិកអាស៊ាន និងបណ្តាប្រទេសដៃគូដទៃ រួមមានចិន ឥណ្ឌា តួកគីយេ... ជាដើម ក្រសួងព័ត៌មានបានស្នើសុំកិច្ចសហការតាមរយៈការចុះអនុស្សរណៈនៃការយោគយល់ ស្តីពីការកិច្ចសហប្រតិបត្តិការលើការអភិវឌ្ឍវិស័យ ព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយ (ប្រព័ន្ធផ្សព្វផ្សាយជំនាន់ថ្មី) ដែលក្នុងនោះការកសាង និងអភិវឌ្ឍន៍មូលធនមនុស្សជាផ្នែកដ៏សំខាន់មួយ។

## ខ. កម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេសនិងការគ្រប់គ្រង

តាមការវាយតម្លៃរបស់ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈ នៃក្រសួងព័ត៌មាន តម្រូវការអភិវឌ្ឍសមត្ថភាពជំនាញ និងការបណ្តុះបណ្តាលឆ្នាំ២០២៥-២០២៨ នឹងត្រូវរៀបចំសម្រាប់មន្ត្រី១ ៩៤២រូប លើមុខជំនាញចំនួន២៤។

យោងតាមការវាយតម្លៃលើតម្រូវការមន្ត្រីបច្ចេកទេស ឬជំនាញវិជ្ជាជីវៈជាប់កិច្ចសន្យា ក្រសួងព័ត៌មានមានតម្រូវការមន្ត្រីបច្ចេកទេស ឬជំនាញវិជ្ជាជីវៈជាប់កិច្ចសន្យាសម្រាប់ការងារបរិវត្តកម្មឌីជីថលនិងប្រព័ន្ធផ្សព្វផ្សាយបែបថ្មី និងការងារបច្ចេកទេសមូលដ្ឋាន។

### ខ.១. កម្មវិធីបណ្តុះបណ្តាលភាពជាអ្នកដឹកនាំស្ថាប័ន

ក្នុងទិសដៅលើកកម្ពស់សមត្ថភាពដឹកនាំ និងគ្រប់គ្រងស្ថាប័ន សម្រាប់ត្រីមាសទី២ នៃឆ្នាំ២០២៥នេះតទៅ វគ្គបណ្តុះបណ្តាលសំខាន់ៗចំនួន១៤វគ្គ នឹងត្រូវរៀបចំសម្រាប់ថ្នាក់ដឹកនាំអង្គភាព (អគ្គនាយករងគ្រប់អគ្គនាយកដ្ឋាន ប្រធាននិងអនុប្រធាននាយកដ្ឋានគ្រប់អគ្គនាយកដ្ឋាន ថ្នាក់ដឹកនាំមន្ទីរព័ត៌មានរាជធានី-ខេត្ត ប្រធាននិងអនុប្រធានការិយាល័យគ្រប់អគ្គនាយកដ្ឋាន) ដោយផ្តោតជាសំខាន់លើការបង្កើនចំណេះដឹង និងភាពប្រទាក់ក្រឡានៃ៖

- យុទ្ធសាស្ត្របញ្ចកោណ -ដំណាក់កាលទី១
- គោលនយោបាយអាទិភាព៦ ចំណុចរបស់រាជរដ្ឋាភិបាល

- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ
- កម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល
- ការងារកែទម្រង់រដ្ឋបាលសាធារណៈរបស់ក្រសួងព័ត៌មាន
- ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់ក្រសួងព័ត៌មាន
- ការងារដឹកនាំកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការនៃក្រសួងព័ត៌មាន
- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យព័ត៌មាននិងសោតទស្សន៍ ឆ្នាំ២០២៤-២០២៨
- ការរៀបចំផែនការសកម្មភាពរបស់អង្គភាពជំនាញ
- ផែនការយុទ្ធសាស្ត្រថវិកា ឆ្នាំ២០២៥-២០២៧
- ការគ្រប់គ្រងគម្រោងចំណូល-ចំណាយតាមឆ្នាំរបស់ក្រសួងព័ត៌មាន
- ភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងស្ថាប័ន
- ពិធីការជាតិ ពិធីការការទូត បដិសណ្ឋារកិច្ច និងអ្នកកាន់កម្មវិធី
- ការរៀបចំបែបបទ និងលិខិតរដ្ឋបាលផ្ទៃក្នុងក្រសួង
- វិធីសាស្ត្រក្នុងការសរសេរសំណើគម្រោង

## ខ.២. កម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេសកម្រិតមូលដ្ឋាន

ដើម្បីលើកកម្ពស់គុណភាពការងារ និងបង្កើនសមត្ថភាពស្ថាប័ន ឆ្នាំ២០២៥នេះ ក្រសួងព័ត៌មាននឹងរៀបចំវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេសចំនួន៣០វគ្គ ដោយចែកចេញជា៣ កម្រិត ដើម្បីកសាងសមត្ថភាពដល់មន្ត្រីជំនាញបច្ចេកទេស នៃគ្រប់អគ្គនាយកដ្ឋានជំនាញចំណុះឱ្យ ក្រសួងព័ត៌មាន (ប្រមាណ២០០រូប)៖

### ទី១. កម្រិតមូលដ្ឋានសម្រាប់ទីភ្នាក់ងារសារព័ត៌មានកម្ពុជា

វគ្គបណ្តុះបណ្តាលកម្រិតមូលដ្ឋានសម្រាប់ទីភ្នាក់ងារសារព័ត៌មានកម្ពុជា (ចំនួន៣៥-៥០រូប) ដែលត្រូវចាប់ផ្តើមពីត្រីមាសទី១ ឆ្នាំ២០២៥ រួមមាន៖

- ប្រវត្តិ និងការវិវត្តន៍នៃសារព័ត៌មាន
- តួនាទី និងការទទួលខុសត្រូវរបស់អ្នកសារព័ត៌មាន
- ប្រភេទនៃសារព័ត៌មាន
- សារព័ត៌មាន និងសង្គម
- មូលដ្ឋានគ្រឹះនៃការសរសេរព័ត៌មាន
- ការស្វែងយល់ពីក្រមសីលធម៌សារព័ត៌មាន
- មូលដ្ឋាននៃការសម្ភាសន៍
- វាក្យសព្ទសម្រាប់សារព័ត៌មាន
- ការអនុវត្តសំណេរផ្អែកលើស្ថានភាពជាក់ស្តែង។

**ទី២. កម្រិតមូលដ្ឋានសម្រាប់ទូរទស្សន៍ជាតិកម្ពុជា**

វគ្គបណ្តុះបណ្តាលកម្រិតមូលដ្ឋានសម្រាប់ទូរទស្សន៍ជាតិកម្ពុជា (ចំនួន៣៥-៥០រូប) ដែលត្រូវចាប់ផ្តើមពីត្រីមាសទី១ ឆ្នាំ២០២៥ រួមមាន៖

- មូលដ្ឋានគ្រឹះនៃការថតវីដេអូ (មុន និងពេលដំណើរការ...)
- ការរៀបចំអត្ថបទសម្រាប់កម្មវិធីទូរទស្សន៍
- តួនាទីពិធីករ/ ពិធីការិនី និងការប្រើប្រាស់រាជសព្ទ/សង្ឃសព្ទ
- មូលដ្ឋាននៃរបៀបកាត់តវីដេអូ
- ការស្វែងយល់ពីឧបករណ៍ផ្សព្វផ្សាយ និងការយល់ដឹងពីការផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយបែបថ្មី
- ការអនុវត្តជាក់ស្តែង។

**ទី៣. កម្រិតមូលដ្ឋានសម្រាប់វិទ្យុជាតិកម្ពុជា**

វគ្គបណ្តុះបណ្តាលកម្រិតមូលដ្ឋានសម្រាប់វិទ្យុជាតិកម្ពុជា ដែលត្រូវចាប់ផ្តើមពីត្រីមាសទី១ ឆ្នាំ២០២៥ រួមមាន៖

- ទស្សនាទានជាមូលដ្ឋានគ្រឹះនៃការផ្សាយវិទ្យុ
- មូលដ្ឋានគ្រឹះនៃការកែសម្រួលសំឡេងតាមកម្មវិធីកុំព្យូទ័រ
- ការរៀបចំអត្ថបទសម្រាប់កម្មវិធីវិទ្យុ
- ការហ្វឹកហាត់សំឡេង
- ការអនុវត្តផ្ទាល់។

**ទី៤. ជំនាញទាក់ទងមុខងារសាធារណៈ**

វគ្គបណ្តុះបណ្តាលកម្រិតមូលដ្ឋានសម្រាប់អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ និងអគ្គនាយកដ្ឋានព័ត៌មាននិងសោតទស្សន៍ (មន្ត្រីជំនាញ៥០រូប) លើជំនាញទាក់ទងមុខងារសាធារណៈ ដែលត្រូវចាប់ផ្តើមពីត្រីមាសទី១ ឆ្នាំ២០២៥ រួមមាន៖

- បរិវត្តកម្មឌីជីថល
- ជំនាញទំនាក់ទំនងសាធារណៈ
- ជំនាញដោះស្រាយបញ្ហា
- ការសរសេររបាយការណ៍
- ការគ្រប់គ្រងទិន្នន័យ និងឯកសារ។

**ខ.៣. កម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេសកម្រិតមធ្យម**

ដើម្បីអភិវឌ្ឍជំនាញ និងសមត្ថភាពស្ថាប័ន (ចំនួន៣៥-៥០រូប) ចាប់ពីឆមាសទី២ ឆ្នាំ២០២៥នេះ ក្រសួងព័ត៌មាននឹងរៀបចំវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេសកម្រិតមធ្យមចំនួន៣វគ្គសម្រាប់៖

**ទី១. ទីភ្នាក់ងារសារព័ត៌មានកម្ពុជា**

វគ្គបណ្តុះបណ្តាល ដែលត្រូវចាប់ផ្តើមធមាសទី២ ឆ្នាំ២០២៥ រួមមាន៖

- ការសិក្សា ស្រាវជ្រាវព័ត៌មាន
- ការរៀបចំមាតិកា និងខ្លឹមសារ
- ប្រព័ន្ធផ្សព្វផ្សាយចម្រុះសម្រាប់សារព័ត៌មាន
- ការផ្ទៀងផ្ទាត់ប្រភពព័ត៌មាន។

**ទី២. ទូរទស្សន៍ជាតិកម្ពុជា**

វគ្គបណ្តុះបណ្តាល ដែលត្រូវចាប់ផ្តើមធមាសទី២ ឆ្នាំ២០២៥ រួមមាន៖

- ការកាត់តឃ្លីបវីដេអូ កម្រិតជំនាញ
- ការយល់ដឹងអំពីក្រាហ្វិកទូរទស្សន៍
- ការគ្រប់គ្រងការផ្សាយផ្ទាល់
- ការគ្រប់គ្រងមាតិកាទូរទស្សន៍
- លំហូរការងារ ការផលិតកម្មវិធីទូរទស្សន៍ បញ្ញាសិប្បនិម្មិត និងកិច្ចសហការលើកម្មវិធីទូរទស្សន៍។

**ទី៣. វិទ្យុជាតិកម្ពុជា**

វគ្គបណ្តុះបណ្តាល ដែលត្រូវចាប់ផ្តើមធមាសទី២ ឆ្នាំ២០២៥ រួមមាន៖

- ការរៀបចំ និងផលិតសម្លេងសម្រាប់ផ្សាយ
- ការរៀបចំក្លីបសម្លេង (ផតខាសត៍) សម្រាប់ការផ្សព្វផ្សាយ
- ប្រតិបត្តិការការផ្សាយវិទ្យុដោយពហុកាមេរ៉ា
- ការគ្រប់គ្រងកម្មវិធីផ្សាយផ្ទាល់។

**ខ.៤. កម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេសកម្រិតខ្ពស់**

ដើម្បីប្រសិទ្ធភាព និងគុណភាពស្ថាប័ន ចាប់ពីត្រីមាសទី៤ ឆ្នាំ២០២៥នេះ ក្រសួងព័ត៌មាននឹងរៀបចំវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេសកម្រិតខ្ពស់ចំនួន៣វគ្គសម្រាប់៖

**ទី១. ទីភ្នាក់ងារសារព័ត៌មានកម្ពុជា**

វគ្គបណ្តុះបណ្តាល ដែលត្រូវចាប់ផ្តើមត្រីមាសទី៤ ឆ្នាំ២០២៥ រួមមាន៖

- ការសិក្សា ស្រាវជ្រាវព័ត៌មាន
- ការរៀបចំមាតិកា និងខ្លឹមសារ
- ការសរសេរបទវិចារណកថា បទយកការណ៍ អត្ថបទវិភាគ...
- ប្រព័ន្ធផ្សព្វផ្សាយចម្រុះសម្រាប់សារព័ត៌មាន
- ការផ្ទៀងផ្ទាត់ប្រភពព័ត៌មាន។

### ទី២. ទូរទស្សន៍ជាតិកម្ពុជា

វគ្គបណ្តុះបណ្តាល ដែលត្រូវចាប់ផ្តើមត្រីមាសទី៤ ឆ្នាំ២០២៥ រួមមាន៖

- ការកែសម្រួលក្លីបវីដេអូកម្រិតឯកទេស
- ការយល់ដឹងអំពីក្រាហ្វិកទូរទស្សន៍
- ការផ្សាយផ្ទាល់
- ការគ្រប់គ្រងមាតិកាទូរទស្សន៍
- លំហូរការងារ និងកិច្ចសហការលើកម្មវិធីទូរទស្សន៍
- ការដឹកនាំផលិតកម្មវិធី។

### ទី៣. វិទ្យុជាតិកម្ពុជា

វគ្គបណ្តុះបណ្តាល ដែលត្រូវចាប់ផ្តើមឆមាសទី២ ឆ្នាំ២០២៥ រួមមាន៖

- យុទ្ធសាស្ត្រនៃការបង្កើតមាតិកាវិទ្យុកម្រិតខ្ពស់
- ការផ្សព្វផ្សាយពីស្ថានីយវិទ្យុដល់សាធារណៈជន
- ការធ្វើទីផ្សារសម្រាប់វិទ្យុ
- ការផលិតឯកសារកម្មវិធីពិស្តារ
- និន្នាការថ្មីក្នុងវិស័យវិទ្យុ
- អគ្គីសនី និងបច្ចេកទេសម៉ាស៊ីនផ្សាយ និងប្រព័ន្ធអេឡិកត្រូនិក។

## គ. ការបង្កើនសមត្ថភាពផ្នែកច្បាប់

ដើម្បីបង្កើនប្រសិទ្ធភាព និងផលិតភាពការងារ ក្នុងគោលបំណងរួមចំណែកសម្រេចបាននូវបេសកកម្មរួមរបស់ក្រសួងព័ត៌មាន ការបង្កើនសមត្ថភាពគ្រប់គ្រងស្ថាប័ន នឹងត្រូវផ្តោតជាសំខាន់លើការលើកកម្ពស់ការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងការគ្រប់គ្រងរដ្ឋបាលផ្ទៃក្នុង។

### គ.១. ការលើកកម្ពស់ការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្ត

ក្នុងគោលបំណងបង្កើនសមត្ថភាពដឹកនាំ និងគ្រប់គ្រងអង្គភាព ក្រសួងព័ត៌មាននឹងរៀបចំសិក្ខាសាលាបណ្តុះបណ្តាលចំនួន៩វគ្គ ជូនដល់ថ្នាក់ដឹកនាំគ្រប់នាយកដ្ឋាន និងគ្រប់អគ្គនាយកដ្ឋាន (ចំនួន៣០០រូប) លើច្បាប់ និងលិខិតបទដ្ឋានសំខាន់ៗ រួមមាន៖

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- ច្បាប់ស្តីពីការបង្កើតក្រសួងព័ត៌មាន
- ច្បាប់ស្តីពីរបបសារព័ត៌មាន
- ច្បាប់ស្តីពីការគ្រប់គ្រងការប្រើប្រាស់ និងចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ
- ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល

- ច្បាប់ស្តីពីបណ្ណសារ
- ធម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មាន
- ច្បាប់ និងអនុក្រឹត្យពាក់ព័ន្ធ។

សិក្ខាសាលាបណ្តុះបណ្តាលលើកកម្ពស់ការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត នេះ នឹងត្រូវរៀបចំនៅរៀងរាល់ត្រីមាស នៃឆ្នាំ២០២៥នេះតទៅ។

### គ.២. ការគ្រប់គ្រងរដ្ឋបាលផ្ទៃក្នុង

ក្នុងគោលបំណងបង្កើនសមត្ថភាពដឹកនាំ និងគ្រប់គ្រងកិច្ចការរដ្ឋបាលផ្ទៃក្នុងប្រកបដោយប្រសិទ្ធភាព ក្រសួងព័ត៌មាននឹងរៀបចំសិក្ខាសាលាបណ្តុះបណ្តាល និងពិគ្រោះយោបល់ដើម្បីស័ក្តិសិទ្ធិភាពការងារជូនដល់ថ្នាក់ដឹកនាំអគ្គនាយកដ្ឋាន នាយកដ្ឋាន មន្ទីរ និងការិយាល័យ (ដែលមានចំនួនសរុប៧០រូប) ដោយត្រូវរៀបចំជារៀងរាល់ត្រីមាស នៃឆ្នាំ២០២៥ ដោយផ្តោតជាសំខាន់លើ៖

- គោលការណ៍ណែនាំស្តីពីនីតិវិធីនិងវិធានការនៃការតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត
- ការគ្រប់គ្រងវត្តមានមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា
- ការគ្រប់គ្រង និងប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យា
- នីតិវិធីនៃការអនុវត្តវិន័យចំពោះមន្ត្រីរាជការស៊ីវិល
- ការវាយតម្លៃគុណាធិបតេយ្យ
- របស់មន្ត្រីរាជការមុនទទួលបានការតែងតាំង
- ការពិនិត្យលក្ខណៈសម្បត្តិបេក្ខជន
- ដែលត្រូវស្នើសុំគ្រឿងឥស្សរិយយស
- ការដាក់មន្ត្រីរាជការឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស
- បទដ្ឋានគតិយុត្តពាក់ព័ន្ធរបស់ក្រសួងព័ត៌មាន (លិខិតរដ្ឋបាលផ្ទៃក្នុងក្រសួង)។

### ឃ. ការលើកកម្ពស់សមត្ថភាពការងារទំនាក់ទំនងសាធារណៈ

ការងារទំនាក់ទំនងសាធារណៈ ផ្តោតសំខាន់លើការរក្សា និងការចែកចាយព័ត៌មានដើម្បីបង្កើនការយល់ដឹង និងភាពជឿជាក់ចំពោះក្រសួង-ស្ថាប័ន។ ប្រសិទ្ធភាពនៃការងារទំនាក់ទំនងសាធារណៈ អាស្រ័យលើសមត្ថភាពក្នុងការបង្កើតទំនាក់ទំនងល្អ និងវិធីសាស្ត្រផ្សព្វផ្សាយ។ ក្នុងន័យនេះ ក្រសួងព័ត៌មានបានកំណត់គោលដៅដើម្បីលើកកម្ពស់សមត្ថភាពជូនដល់មន្ត្រីរាជការចំនួនប្រមាណ៧០នាក់លើ៖

### ឃ.១. ការគ្រប់គ្រងលំហព័ត៌មាន និងសន្តិសុខព័ត៌មាន

ចាប់ពីត្រីមាសទី១ និងទី៣ នៃឆ្នាំ២០២៥ ក្រសួងព័ត៌មាននឹងរៀបចំបាឋកថាចំនួន២

ដង ជូនដល់ថ្នាក់ដឹកនាំរបស់ក្រសួង គ្រប់អគ្គនាយកដ្ឋាន និងគ្រប់នាយកដ្ឋាន (៣០០រូប) លើប្រព័ន្ធគ្រប់គ្រងព័ត៌មានប្រកបដោយប្រសិទ្ធភាព គុណភាព និងភាពប្រទាក់ក្រឡា។

### ឃ.២. សមត្ថភាពគ្រប់គ្រងព័ត៌មាន និងសាធារណមតិមូលដ្ឋាន

ចាប់ពីត្រីមាសទី១ និងទី៣ នៃឆ្នាំ២០២៥ មន្ត្រីទទួលបន្ទុកព័ត៌មាន និងសាធារណមតិ (ចំនួន៥ រូប) នៃមន្ទីរព័ត៌មានរាជធានី-ខេត្ត នឹងត្រូវទទួលការបណ្តុះបណ្តាលចំនួន២វគ្គ ដើម្បីអភិវឌ្ឍសមត្ថភាពមន្ត្រីព័ត៌មាន និងសាធារណមតិរាជធានី-ខេត្ត។

### ឃ.៣. ការលើកកម្ពស់ការទូតព័ត៌មាន

ចាប់ពីត្រីមាសទី១ និងទី៣ នៃឆ្នាំ២០២៥ គ្រប់អគ្គនាយករងនៃគ្រប់អគ្គនាយកដ្ឋានដែលទទួលបន្ទុកសម្របសម្រួលការងារសហប្រតិបត្តិការអន្តរជាតិ រួមជាមួយថ្នាក់ដឹកនាំនិងមន្ត្រីនៃនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ នឹងត្រូវទទួលការបណ្តុះបណ្តាលចំនួន៦វគ្គ ដើម្បី៖

- ស្វែងយល់ពីក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការអាស៊ាន និងរចនាសម្ព័ន្ធការងារ
- បង្កើនការយល់ដឹងពីក្របខណ្ឌកិច្ចសហប្រតិបត្តិការមេគង្គ និងទ្វេភាគី និង
- លើកកម្ពស់ការយល់ដឹងលើក្របខណ្ឌអង្គការសហប្រជាជាតិ និងសហគមន៍អ៊ឺរ៉ុប ជាដើម។

### ឃ.៤. សណ្តាប់ធ្នាប់នៃកិច្ចប្រជុំ និងព្រឹត្តិការណ៍

ទន្ទឹមនេះដែរ នៅត្រីមាសទី២ និងទី៤ នៃឆ្នាំ២០២៥ ក្រសួងព័ត៌មាននឹងចាប់ផ្តើមការបណ្តុះបណ្តាលចំនួន២វគ្គ ដល់អគ្គនាយករង នៃគ្រប់អគ្គនាយកដ្ឋានដែលទទួលបន្ទុកសម្របសម្រួលការងារសហប្រតិបត្តិការអន្តរជាតិ និងថ្នាក់ដឹកនាំនិងមន្ត្រីនៃនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិលើការងារពិធីការជាតិនិងពិធីការការទូត បដិសណ្ឋារកិច្ច និងការកាន់កម្មវិធី ដោយនឹងសហការជាមួយវិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិ នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

### ឃ.៥. ការបង្កើនកិច្ចសហប្រតិបត្តិការ និងការគាំទ្រ

ក្នុងទិសដៅបង្កើនប្រសិទ្ធភាព និងផលិតភាពការងារ គ្រប់អង្គភាពជំនាញចំណុះឱ្យក្រសួងព័ត៌មាន ត្រូវលើកកម្ពស់សមត្ថភាព ដើម្បីស្វែងរកកិច្ចសហប្រតិបត្តិការ ឬការគាំទ្រពីដៃគូអភិវឌ្ឍ ដែលមានរបៀបវារៈការងារក្នុងវិស័យព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយ។ ក្នុងន័យនេះ ក្រសួងព័ត៌មាននឹងផ្តល់ជូននូវវគ្គបណ្តុះបណ្តាលស្តីពីការរៀបចំបែបបទ និងវិធីសាស្ត្រក្នុងការសរសេរសំណើគម្រោង ដោយត្រូវចាប់ផ្តើមពីត្រីមាសទី២ និងទី៣ នៃឆ្នាំ២០២៥នេះ។

តារាងផែនការសកម្មភាព និងតម្រូវការថវិកាសម្រាប់ការកសាងនិងអភិវឌ្ឍន៍មូលធនមនុស្សក្នុងវិស័យព័ត៌មាន និងសោតទស្សន៍ ឆ្នាំ២០២៥ ជាឧបសម្ព័ន្ធ នៃផែនការសកម្មភាពនេះ។

## ៤. តម្រូវការ និងប្រភពថវិកា

### ៤.១. តម្រូវការ

យោងតាមតារាងផែនការសកម្មភាព ចំនួនវគ្គបណ្តុះបណ្តាលដែលត្រូវផ្តល់ជូនសម្រាប់ឆ្នាំ២០២៥ មានចំនួន៧៨ វគ្គ ដែលចែកចេញជា៖

- ២២វគ្គ សម្រាប់ត្រីមាសទី១
- ២០វគ្គ សម្រាប់ត្រីមាសទី២
- ២២វគ្គ សម្រាប់ត្រីមាសទី៣ និង
- ១៤វគ្គ សម្រាប់ត្រីមាសទី៤។

សម្រាប់វគ្គបណ្តុះបណ្តាលទាំង៧៨ តម្រូវការថវិកាសរុបចំនួន៩៤៦លានរៀល ក្នុងនោះសម្រាប់វគ្គចំនួន៖

- ២២វគ្គ នៅត្រីមាសទី១ ត្រូវការថវិកា **២៥៦លានរៀល**
- ២០វគ្គ នៅត្រីមាសទី២ ត្រូវការថវិកា **២០៩លានរៀល**
- ២២វគ្គ នៅត្រីមាសទី៣ ត្រូវការថវិកា **៣២៧លានរៀល**
- ១៤វគ្គ នៅត្រីមាសទី៤ ត្រូវការថវិកា **១៥៤លានរៀល**។

### ៤.២. ប្រភពថវិកា

ថវិកាទ្រទ្រង់វគ្គបណ្តុះបណ្តាលសម្រាប់ឆ្នាំ២០២៥ ជាថវិកាដែលត្រូវស្នើតាមរយៈថវិកាកម្មវិធី ហិរញ្ញប្បទានដៃគូ និងប្រភពស្របច្បាប់ផ្សេងៗ។

## ៥. យន្តការអនុវត្ត និងការតាមដាននិងវាយតម្លៃ

### ៥.១. គណៈកម្មការតម្រង់ទិស និងក្រុមការងារបច្ចេកទេស

ក្រសួងព័ត៌មាននឹងបង្កើតគណៈកម្មការតម្រង់ទិស និងក្រុមការងារបច្ចេកទេស សម្រាប់ដឹកនាំ តម្រង់ទិស និងរៀបចំត្រួតពិនិត្យការរៀបចំវគ្គ ការសិក្សា និងការអនុវត្តផ្ទាល់។

គណៈកម្មការតម្រង់ទិសនឹងត្រូវដឹកនាំផ្ទាល់ដោយរដ្ឋមន្ត្រីក្រសួងព័ត៌មាន និងមានរដ្ឋលេខាធិការ១រូប ជាអនុប្រធានអចិន្ត្រៃយ៍។ សមាសភាពនៃគណៈកម្មការមានថ្នាក់ដឹកនាំក្រសួង និងអគ្គនាយកដ្ឋាន រួមជាមួយទីប្រឹក្សាក្រសួងនិងនិវត្តន៍ជន ដែលមានបទពិសោធខ្ពស់។ គណៈកម្មការតម្រង់ទិសនឹងត្រូវកោះប្រជុំ៤ដង ក្នុងឆ្នាំ ឬលើសនេះតាមការណែនាំរបស់ប្រធាន។

ក្រុមការងារបច្ចេកទេស ត្រូវដឹកនាំដោយអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មការតម្រង់ទិស និងមានសមាជិកជាគ្រូបង្គោល គ្រូឧទ្ទេស និងគ្រូជំនួយ។ ក្រុមការងារបច្ចេកទេសត្រូវទទួលខុសត្រូវលើការរៀបចំកម្មវិធីសិក្សា និងការអនុវត្តផ្ទាល់។ ក្រុមការងារបច្ចេកទេស មានលេខាធិការដ្ឋាន ១ជាជំនួយការ ដែលត្រូវដឹកនាំដោយថ្នាក់ដឹកនាំក្រសួង ១រូប។

### ៥.២. មណ្ឌលបណ្តុះបណ្តាល និងវិក្រឹតការវិជ្ជាជីវៈសារព័ត៌មាន

មណ្ឌលបណ្តុះបណ្តាល និងវិក្រឹតការវិជ្ជាជីវៈសារព័ត៌មាន ដើរតួនាទីជាសេនាធិការឱ្យលេខាធិការដ្ឋាន នៃក្រុមការងារបច្ចេកទេស ដោយត្រូវសម្របសម្រួលការងារគ្រូបង្គោល គ្រូឧទ្ទេស និងគ្រូជំនួយ និងរៀបចំវគ្គបណ្តុះបណ្តាល ព្រមទាំងរៀបចំទិន្នន័យដែលទទួលបានពីការបណ្តុះបណ្តាលទាំងអស់សម្រាប់ការរៀបចំផែនការបន្ត។

មណ្ឌលបណ្តុះបណ្តាល និងវិក្រឹតការវិជ្ជាជីវៈសារព័ត៌មានត្រូវធ្វើការវាយតម្លៃពីប្រសិទ្ធភាពនៃវគ្គបណ្តុះបណ្តាល និងផ្អែកលើលទ្ធផលនៃវគ្គទាំងអស់ត្រូវសិក្សាបន្តពីតម្រូវការលើការធ្វើវិក្រឹតការវិជ្ជាជីវៈសារព័ត៌មាន ដល់មន្ត្រីរាជការស៊ីវិលរបស់ក្រសួង និងមន្ត្រីពាក់ព័ន្ធប្រចាំឆ្នាំ សម្រាប់ការរៀបចំផែនការបន្ត។

### ៥.៣. សូចនាករតាមដាន

ដើម្បីធានាបាននូវប្រសិទ្ធភាព និងសង្គតិភាពនៃការអនុវត្តផែនការសកម្មភាពនេះ មណ្ឌលបណ្តុះបណ្តាល និងវិក្រឹតការវិជ្ជាជីវៈសារព័ត៌មានត្រូវសម្របសម្រួល ពិនិត្យ តាមដាន និងវាយតម្លៃលើរាល់បណ្តាវគ្គបណ្តុះបណ្តាល ដោយត្រូវរៀបចំជារបាយការណ៍សម្រាប់វគ្គសិក្សានីមួយៗឱ្យបានត្រឹមត្រូវ។

តាមរយៈ **ផែនការសកម្មភាពស្តីពីការកសាង និងអភិវឌ្ឍន៍មូលធនមនុស្សក្នុងវិស័យព័ត៌មាន និងសោតទស្សន៍ ឆ្នាំ២០២៥-២០២៨** ក្រសួងនឹង៖

- កសាង និងអភិវឌ្ឍជំនាញវិជ្ជាជីវៈ (បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់...) ដោយបញ្ជូនមន្ត្រីរាជការប្រមាណ ២-៣រូបសម្រាប់សិក្សាថ្នាក់បរិញ្ញាបត្រ និងជំនាញពាក់ព័ន្ធនៅក្រៅប្រទេស នៅឆ្នាំ២០២៥ និងចាត់បញ្ជូននៅឆ្នាំបន្តបន្ទាប់
- បណ្តុះបណ្តាលភាពជាអ្នកដឹកនាំស្ថាប័នដល់អគ្គនាយករង គ្រប់អគ្គនាយកដ្ឋាន ប្រធាននិងអនុប្រធាននាយកដ្ឋានគ្រប់អគ្គនាយកដ្ឋាន និងប្រធាននិងអនុប្រធានការិយាល័យគ្រប់អគ្គនាយកដ្ឋាន ដែលមានចំនួនសរុប២៥០នាក់
- បណ្តុះបណ្តាលជំនាញបច្ចេកទេសកម្រិតមូលដ្ឋាន មធ្យម និងកម្រិតខ្ពស់ដល់៖
  - ✓ មន្ត្រីជំនាញបច្ចេកទេស នៃអគ្គនាយកដ្ឋានទីភ្នាក់ងារសារព័ត៌មានកម្ពុជា ចំនួន៥០រូប/កម្រិត
  - ✓ មន្ត្រីជំនាញបច្ចេកទេស នៃអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា ចំនួន៥០រូប/កម្រិត
  - ✓ មន្ត្រីជំនាញបច្ចេកទេស នៃអគ្គនាយកដ្ឋានវិទ្យុជាតិកម្ពុជា ចំនួន៥០រូប/កម្រិត
  - ✓ ជំនាញទាក់ទងមុខងារសាធារណៈ (អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និងអគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍) ចំនួន៥០រូប/កម្រិត

- ការបង្កើនសមត្ថភាពផ្នែកច្បាប់សម្រាប់ការគ្រប់គ្រងអង្គភាពដល់ថ្នាក់ដឹកនាំនាយកដ្ឋាន និងអគ្គនាយកដ្ឋាន ចំនួន៣០០នាក់ និង
- លើកកម្ពស់សមត្ថភាពការងារទំនាក់ទំនងសាធារណៈ និងកិច្ចសហប្រតិបត្តិការជូនថ្នាក់ដឹកនាំក្រសួង អគ្គនាយកដ្ឋាន និងនាយកដ្ឋាន ចំនួន៣០០នាក់ និងមន្ត្រីព័ត៌មាននៃមន្ទីរព័ត៌មានរាជធានី-ខេត្ត ចំនួន៣/រាជធានី-ខេត្ត។

## ៦. សេចក្តីសន្និដ្ឋាន

ឯកសារ **ផែនការសកម្មភាពស្តីពីការកសាង និងអភិវឌ្ឍន៍មូលធនមនុស្សក្នុងវិស័យព័ត៌មាន និងសោតទស្សន៍ ឆ្នាំ២០២៥-២០២៨** ជាផែនទីចង្អុលបង្ហាញផ្លូវក្នុងការរៀបចំធនធានមនុស្សក្នុងក្រសួងព័ត៌មានប្រកបដោយសក្តានុពល តាមរយៈការចែករំលែកនិងផ្តល់នូវចំណេះដឹង ជំនាញបច្ចេកទេស និងការបណ្តុះស្មារតីមនសិការវិជ្ជាជីវៈដល់មន្ត្រីរាជការ ដើម្បីសហការចូលរួមចំណែកក្នុងការប្រែក្លាយក្រសួងព័ត៌មានជា **ស្ថាប័នទំនាក់ទំនងសាធារណៈរបស់រាជរដ្ឋាភិបាលប្រកបដោយបុរេសកម្ម សកម្ម អន្តរសកម្ម ប្រសិទ្ធភាព និងប្រសិទ្ធផល** ដើម្បីគ្រប់គ្រងលំហាព័ត៌មាន និងសហការធានាសន្តិសុខព័ត៌មាន និងបំពេញតួនាទីស្នូលនិងមុខងារគាំទ្ររបស់ក្រសួងឱ្យមានប្រសិទ្ធភាពខ្ពស់។

ក្នុងរយៈពេល១ឆ្នាំ (២០២៥) ក្រសួងព័ត៌មានជឿថា នឹងទទួលបាននូវការលើកកម្ពស់ចំណេះដឹងលើផ្នែកជំនាញបច្ចេកទេសនិងការគ្រប់គ្រង ការបង្កើនសមត្ថភាពផ្នែកច្បាប់សម្រាប់ការគ្រប់គ្រងអង្គភាព និងការលើកកម្ពស់សមត្ថភាពការងារទំនាក់ទំនងសាធារណៈនិងកិច្ចសហប្រតិបត្តិការសម្រាប់មន្ត្រីរាជការក្រសួងព័ត៌មាន និងមន្ទីរព័ត៌មានរាជធានី-ខេត្ត ដែលការប្រតិបត្តិនេះ នឹងក្លាយជាបទពិសោធន៍សម្រាប់បណ្តាឆ្នាំបន្តបន្ទាប់៕

*********

# ផែនការសកម្មភាពសម្រាប់ការកសាងនិងអភិវឌ្ឍន៍មូលធនមនុស្ស
# ក្នុងវិស័យព័ត៌មាន និងសោតទស្សន៍ ឆ្នាំ២០២៥

| ល.រ. | គោលបំណង | សកម្មភាពបណ្តុះបណ្តាល | លទ្ធផលរំពឹងទុក | ចំនួនវគ្គ | កាលបរិច្ឆេទ (ឆ្នាំ២០២៥) | | | |
|---|---|---|---|---|---|---|---|---|
| | | | | | ត្រីមាសទី១ | ត្រីមាសទី២ | ត្រីមាសទី៣ | ត្រីមាសទី៤ |
| **១.** | **ការកសាង និងអភិវឌ្ឍជំនាញវិជ្ជាជីវៈ (បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់...)** | | | | | | | |
| **ក.** | **ក្របខណ្ឌជាតិ** | | | | | | | |
| ១. | បណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា | បណ្តុះបណ្តាលជំនាញបរិញ្ញាបត្រឌីជីថល នៅវិទ្យាស្ថានបច្ចេកវិទ្យាឌីជីថល | បរិញ្ញាបត្រវិទ្យាសាស្ត្រកុំព្យូទ័រ (៥រូប) | ក.ប.ទ. | ✓ | | | |
| | | ស្នើសុំអាហារូបករណ៍ ***ទេពកោសល្យឌីជីថល តេជោ*** សម្រាប់សិក្សាថ្នាក់បរិញ្ញាបត្រជំនាញបច្ចេកវិទ្យាឌីជីថល | - ៣ កន្លែងនៅបណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា<br>- ១ កន្លែងនៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា<br>- ១ កន្លែងនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ<br>- ១ កន្លែងនៅសាកលវិទ្យាជាតិគ្រប់គ្រង | - | ✓ | | | |
| | | វគ្គបណ្តុះបណ្តាលនៅវិទ្យាស្ថានអភិបាលកិច្ចឌីជីថលលើ៖<br>- ចំណេះដឹងជំនាញផ្នែកឌីជីថល (ជំនាញ ២ ចំណេះដឹង ១ កសាងមូលធនមនុស្សឌីជីថល)<br>- កម្មវិធីភាពជាអ្នកដឹកនាំឌីជីថល | មន្ត្រីរាជការចំនួន ១៥រូប/វគ្គ | ក.ប.ទ. | ✓ | | | |
| ២. | សាលាភូមិន្ទរដ្ឋបាល | វគ្គវិក្រឹតការមន្ត្រីជាន់ខ្ពស់ | ៤រូប/ឆ្នាំ | ស.ភ.រ. | ✓ | | | |
| | | វគ្គវិក្រឹតការមន្ត្រីមធ្យម | ២រូប/ឆ្នាំ | | ✓ | | | |
| | | វគ្គវិក្រឹតការមន្ត្រីគ្រប់គ្រងរដ្ឋបាល | ២រូប/ឆ្នាំ | | ✓ | | | |
| ៣. | កិច្ចសហប្រតិបត្តិការជាមួយសាកលវិទ្យាល័យភ្នំពេញអន្តរជាតិ (ស.ភ.ព.អ) | កម្មវិធីបណ្តុះបណ្តាលធនធានមនុស្សក្នុងវិស័យព័ត៌មាន និងសោតទស្សន៍ | សហការបង្កើតមហាវិទ្យាល័យព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយ | ស.ភ.ព.អ | ✓ | - | - | - |
| | | រៀបចំយន្តការសម្រាប់ដឹកនាំនិងគ្រប់គ្រងកិច្ចសហប្រតិបត្តិការ និងរៀបចំបច្ចេកទេសនិងមុខវិជ្ជាបង្រៀន | ក្រុមការងារដឹកនាំ និងគ្រប់គ្រង | - | ✓ | - | - | - |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ខ. | **ក្របខណ្ឌអន្តរជាតិ** | | | | | | | |
| ១. | កិច្ចសហប្រតិបត្តិការទ្វេភាគីជាមួយរដ្ឋជាសមាជិកអាស៊ាន | - សំណើសុំអាហារូបករណ៍តាមជំនាញ<br>- កិច្ចសហប្រតិបត្តិការលើការបណ្តុះបណ្តាលជំនាញបច្ចេកទេស<br>- រៀបចំអនុស្សរណៈនៃការយោគយល់ | បញ្ជូនមន្ត្រីសម្រាប់កម្មវិធីសិក្សាកម្រិតបរិញ្ញាបត្រ និង/ឬបរិញ្ញាបត្រជាន់ខ្ពស់ | ៤ | ១ | ១ | - | - |
| ២. | កិច្ចសហប្រតិបត្តិការទ្វេភាគី (ចិន ឥណ្ឌា ម៉ាឡេស៊ី តួកគី ជាដើម) | | | | ១ | ១ | - | - |
| ២. | **កម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេស និងការគ្រប់គ្រង** | | | | | | | |
| ក. | **កម្មវិធីបណ្តុះបណ្តាលភាពជាអ្នកដឹកនាំស្ថាប័ន** | | | | | | | |
| ១. | លើកកម្ពស់សមត្ថភាពគ្រប់គ្រង និងចំណេះដឹងពីគោលនយោបាយ និងផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលតាមរយៈសិក្ខាសាលា | យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ | សមាសភាពទទួលការបណ្តុះបណ្តាល (២៥០នាក់)៖<br>- អគ្គនាយករង គ្រប់អគ្គនាយកដ្ឋាន<br>- ប្រធាន និងអនុប្រធាននាយកដ្ឋាន គ្រប់អគ្គនាយកដ្ឋាន<br>- ថ្នាក់ដឹកនាំមន្ទីរព័ត៌មានរាជធានី-ខេត្ត<br>- ប្រធាន និងអនុប្រធានការិយាល័យ គ្រប់អគ្គនាយកដ្ឋាន | ២ | - | ១ | ១ | - |
| ២. | | គោលនយោបាយអាទិភាព៦ចំណុចរបស់រាជរដ្ឋាភិបាល | | ២ | - | ១ | ១ | - |
| ៣. | | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល | | ២ | - | ១ | ១ | - |
| ៤. | | - ការងារកែទម្រង់រដ្ឋបាលសាធារណៈរបស់ក្រសួងព័ត៌មាន<br>- ការងារដឹកនាំកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការនៃក្រសួងព័ត៌មាន | | ២ | - | ១ | ១ | - |
| ៥. | | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យព័ត៌មាននិងសោតទស្សន៍ ឆ្នាំ២០២៤-២០២៨ | | ២ | ១ | - | ២០ | - |
| ៦. | | - ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់ក្រសួងព័ត៌មាន និង<br>- ការរៀបចំផែនការសកម្មភាពរបស់អង្គភាពជំនាញ | | ១ | ១ | - | - | - |
| ៧. | | ផែនការយុទ្ធសាស្ត្រថវិកា ឆ្នាំ២០២៥-២០២៧ និងគម្រោងចំណូល-ចំណាយតាមឆ្នាំរបស់ក្រសួងព័ត៌មាន | | ១ | ១ | - | - | - |
| ៨. | | ភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងស្ថាប័ន | | ១ | ១ | - | - | - |
| ៩. | | វិធីសាស្ត្រក្នុងការសរសេរសំណើគម្រោង | | ១ | - | ១ | - | - |
| ខ. | **កម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេសកម្រិតមូលដ្ឋាន** | | | | | | | |
| ១. | **ទីភ្នាក់ងារសារព័ត៌មានកម្ពុជា** | | | | | | | |
| | | ប្រវត្តិ និងការវិវត្តន៍នៃសារព័ត៌មាន | | ១ | ១ | - | - | - |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | លើកកម្ពស់គុណភាពការងារ និងបង្កើនសមត្ថភាពបច្ចេកទេសអគ្គនាយកដ្ឋាន | តួនាទី និងការទទួលខុសត្រូវរបស់អ្នកសារព័ត៌មាន | មន្ត្រីជំនាញបច្ចេកទេសនៃអគ្គនាយកដ្ឋានទីភ្នាក់ងារសារព័ត៌មានកម្ពុជា (៥០រូប) | | | | | |
| | | ប្រភេទនៃសារព័ត៌មាន | | | | | | |
| | | សារព័ត៌មាន និងសង្គម | | | | | | |
| | | មូលដ្ឋានគ្រឹះនៃការសរសេរព័ត៌មាន | | | | | | |
| | | ការស្វែងយល់ពីក្រមសីលធម៌សារព័ត៌មាន | | | | | | |
| | | មូលដ្ឋាននៃការសម្ភាសន៍ | | | | | | |
| | | វាក្យសព្ទសម្រាប់សារព័ត៌មាន | | ២ | ១ | ១ | | |
| | | ការអនុវត្តសំណេរផ្អែកលើស្ថានភាពជាក់ស្តែង | | ៤ | ១ | ១ | ១ | ១ |
| ២. | **ទូរទស្សន៍ជាតិកម្ពុជា** | | | | | | | |
| | លើកកម្ពស់គុណភាពការងារ និងបង្កើនសមត្ថភាពបច្ចេកទេសអគ្គនាយកដ្ឋាន | មូលដ្ឋានគ្រឹះនៃការថតវីដេអូ (មុន និងពេលដំណើរការ...) | មន្ត្រីជំនាញបច្ចេកទេស (៥០រូប) | ១ | ១ | - | - | - |
| | | ការរៀបចំអត្ថបទសម្រាប់កម្មវិធីទូរទស្សន៍ | | | | | | |
| | | តួនាទីពិធីករ/ ពិធីការិនី និងការប្រើប្រាស់រាជសព្ទ/សង្ឃសព្ទ | | | | | | |
| | | មូលដ្ឋាននៃរបៀបកាត់តវីដេអូ | | | | | | |
| | | ការស្វែងយល់ពីឧបករណ៍ផ្សព្វផ្សាយ និងការយល់ដឹងពីការផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយបែបថ្មី | | | | | | |
| | | ការអនុវត្តជាក់ស្តែង | | ៤ | ១ | ១ | ១ | ១ |
| ៣. | **វិទ្យុជាតិកម្ពុជា** | | | | | | | |
| | លើកកម្ពស់គុណភាពការងារ និងបង្កើនសមត្ថភាពបច្ចេកទេសអគ្គនាយកដ្ឋាន | ទស្សនាទានជាមូលដ្ឋានគ្រឹះនៃការផ្សាយវិទ្យុ | មន្ត្រីជំនាញបច្ចេកទេស (៥០រូប) | ១ | ១ | - | - | - |
| | | មូលដ្ឋានគ្រឹះនៃការកែសម្រួលសំឡេងតាមកម្មវិធីកុំព្យូទ័រ | | | | | | |
| | | ការរៀបចំអត្ថបទសម្រាប់កម្មវិធីវិទ្យុ | | | | | | |
| | | ការហ្វឹកហាត់សំឡេង | | | | | | |
| | | ការអនុវត្តផ្ទាល់ | | ៤ | ១ | ១ | ១ | ១ |
| ៤. | **ជំនាញទាក់ទងមុខងារសាធារណៈ** | | | | | | | |
| | | បរិវត្តកម្មឌីជីថល | មន្ត្រីជំនាញ (៥០រូប)៖ | ៣ | ១ | - | ១ | ១ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | ជំនាញទំនាក់ទំនងសាធារណៈ | - អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ<br>- អគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍ | ៣ | - | ១ | ១ | ១ |
| | | ជំនាញដោះស្រាយបញ្ហា | | ៣ | ១ | - | ១ | ១ |
| | | ការសរសេររបាយការណ៍ | | ២ | ១ | ១ | - | - |
| | | ការគ្រប់គ្រងទិន្នន័យ និងឯកសារ | | ២ | ១ | - | ១ | - |
| **គ.** | **កម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេសកម្រិតមធ្យម** | | | | | | | |
| ១. | **ទីភ្នាក់ងារសារព័ត៌មានកម្ពុជា** | | | | | | | |
| | អភិវឌ្ឍជំនាញ និងសមត្ថភាពស្ថាប័ន ដើម្បីលើកកម្ពស់គុណភាពព័ត៌មាន | ការសិក្សា ស្រាវជ្រាវព័ត៌មាន<br>ការរៀបចំមាតិកា និងខ្លឹមសារ<br>ប្រព័ន្ធផ្សព្វផ្សាយចម្រុះសម្រាប់សារព័ត៌មាន<br>ការផ្ទៀងផ្ទាត់ប្រភពព័ត៌មាន | - មន្ត្រីបច្ចេកទេស ៥០ ដែលបានទទួលការបណ្តុះបណ្តាលនៅកម្រិតមូលដ្ឋាន<br>- អ្នកយកព័ត៌មាន<br>- អ្នកនិពន្ធ និងសរសេរអត្ថបទ | ១ | - | - | ១ | - |
| ២. | **ទូរទស្សន៍ជាតិកម្ពុជា** | | | | | | | |
| | អភិវឌ្ឍជំនាញ និងសមត្ថភាពស្ថាប័ន ដើម្បីលើកកម្ពស់គុណភាពការផ្សាយ | ការកាត់តឃ្លីបវីដេអូ កម្រិតជំនាញ<br>ការយល់ដឹងអំពីក្រាហ្វិកទូរទស្សន៍<br>ការគ្រប់គ្រងផ្សាយផ្ទាល់<br>ការគ្រប់គ្រងកម្មវិធីទូរទស្សន៍<br>លំហូរការងារ ការផលិតកម្មវិធីទូរទស្សន៍ បញ្ញាសិប្បនិម្មិត និងកិច្ចសហការលើកម្មវិធីទូរទស្សន៍ | - មន្ត្រីបច្ចេកទេស ៥០ ដែលបានទទួលការបណ្តុះបណ្តាលនៅកម្រិតមូលដ្ឋាន<br>- អគ្គនាយករង (ការងារបច្ចេកទេស)<br>- អ្នកយកព័ត៌មាន<br>- អ្នកនិពន្ធ និងសរសេរអត្ថបទ | ១ | - | - | ១ | - |
| ៣. | **វិទ្យុជាតិកម្ពុជា** | | | | | | | |
| | អភិវឌ្ឍជំនាញ និងសមត្ថភាពស្ថាប័ន ដើម្បីលើកកម្ពស់គុណភាពការផ្សាយ | ការរៀបចំ និងផលិតសម្លេងសម្រាប់ផ្សាយ<br>ការរៀបចំក្លីបសម្លេង (ផតខាសត៍) សម្រាប់ការផ្សព្វផ្សាយ<br>ប្រតិបត្តិការការផ្សាយវិទ្យុដោយពហុកាមេរ៉ា<br>ការគ្រប់គ្រងកម្មវិធីផ្សាយផ្ទាល់ | - មន្ត្រីបច្ចេកទេស ៥០ ដែលបានទទួលការបណ្តុះបណ្តាលនៅកម្រិតមូលដ្ឋាន<br>- អ្នកយកព័ត៌មាន<br>- អ្នកនិពន្ធ និងសរសេរអត្ថបទ | ១ | - | - | ១ | - |
| **ឃ.** | **កម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេសកម្រិតខ្ពស់** | | | | | | | |
| ១. | **ទីភ្នាក់ងារសារព័ត៌មានកម្ពុជា** | | | | | | | |
| | ប្រសិទ្ធភាព និងគុណភាពស្ថាប័ន | ការសិក្សា ស្រាវជ្រាវព័ត៌មាន<br>ការរៀបចំមាតិកា និងខ្លឹមសារ<br>ការសរសេរបទវិចារណកថា បទយកការណ៍ អត្ថបទវិភាគ... | - អ្នកយកព័ត៌មាន<br>- អ្នកនិពន្ធ និងសរសេរអត្ថបទ | ១ | - | - | - | ១ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | ប្រព័ន្ធផ្សព្វផ្សាយចម្រុះសម្រាប់សារព័ត៌មាន | | | | | | |
| | | ការផ្ទៀងផ្ទាត់ប្រភពព័ត៌មាន | | | | | | |
| ២. | ទូរទស្សន៍ជាតិកម្ពុជា | | | | | | | |
| | ប្រសិទ្ធភាព និងគុណភាពស្ថាប័ន | ការកែសម្រួលក្លីបវីដេអូកម្រិតឯកទេស | - អ្នកយកព័ត៌មាន<br>- អ្នកនិពន្ធ និងសរសេរអត្ថបទ | ១ | - | - | - | ១ |
| | | ការយល់ដឹងអំពីក្រាហ្វិកទូរទស្សន៍ | | | | | | |
| | | ការផ្សាយផ្ទាល់ | | | | | | |
| | | ការគ្រប់គ្រងមាតិកាទូរទស្សន៍ | | | | | | |
| | | លំហូរការងារ និងកិច្ចសហការលើកម្មវិធីទូរទស្សន៍ | | | | | | |
| | | ការដឹកនាំផលិតកម្មវិធី | | | | | | |
| ៣. | **វិទ្យុជាតិកម្ពុជា** | | | | | | | |
| | ប្រសិទ្ធភាព និងគុណភាពស្ថាប័ន | យុទ្ធសាស្ត្រនៃការបង្កើតមាតិកាវិទ្យុ | - អ្នកយកព័ត៌មាន<br>- អ្នកនិពន្ធ និងសរសេរអត្ថបទ | ១ | - | - | - | ១ |
| | | ការផ្សព្វផ្សាយពីស្ថានីយវិទ្យុដល់សាធារណៈជន | | | | | | |
| | | ការធ្វើទីផ្សារសម្រាប់វិទ្យុ | | | | | | |
| | | ការផលិតឯកសារកម្មវិធីពិស្តារ | | | | | | |
| | | និន្នាការថ្មីក្នុងវិស័យវិទ្យុ | | | | | | |
| | | អគ្គីសនី និងបច្ចេកទេសម៉ាស៊ីនផ្សាយ និងប្រព័ន្ធអេឡិកត្រូនិក | | | | | | |
| ៣. | **ការបង្កើនសមត្ថភាពផ្នែកច្បាប់សម្រាប់ការគ្រប់គ្រងអង្គភាព** | | | | | | | |
| **ក.** | **ការលើកកម្ពស់ការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ** | | | | | | | |
| ១. | បង្កើនសមត្ថភាពដឹកនាំ និងគ្រប់គ្រងអង្គភាព | រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា | សិក្ខាសាលាបណ្តុះបណ្តាលជូនដល់ថ្នាក់ដឹកនាំនាយកដ្ឋាន និងអគ្គនាយកដ្ឋាន និងថ្នាក់ដឹកនាំមន្ទីរព័ត៌មានរាជធានី-ខេត្ត (៣០០នាក់) | ៤ | ១ | ១ | ១ | ១ |
| | | - ច្បាប់ស្តីពីការបង្កើតក្រសួងពត៌មាន<br>- ច្បាប់ស្តីពីរបបសារព័ត៌មាន | | | | | | |
| | | ច្បាប់ស្តីពីការគ្រប់គ្រងការប្រើប្រាស់ និងចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ | | | | | | |
| | | ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា | | | | | | |
| | | ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល | | | | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | ច្បាប់ស្ដីពីបណ្ណសារ | | | | | | |
| | | ធម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មាន | | | | | | |
| | | ច្បាប់ និងអនុក្រឹត្យពាក់ព័ន្ធ | | | | | | |
| **៣.** | **ការគ្រប់គ្រងរដ្ឋបាលផ្ទៃក្នុង** | | | | | | | |
| ២. | សមត្ថភាពគ្រប់គ្រងការងាររដ្ឋបាល | គោលការណ៍ណែនាំស្ដីពីនីតិវិធីនិងវិធានការនៃការតាក់តែងសេចក្ដីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត<br>ការគ្រប់គ្រងវត្តមានមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា<br>ការគ្រប់គ្រង និងប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យា<br>នីតិវិធីនៃការអនុវត្តវិន័យចំពោះមន្ត្រីរាជការស៊ីវិល<br>ការវាយតម្លៃគុណាធិបតេយ្យរបស់មន្ត្រីរាជការមុនទទួលបានការតែងតាំង<br>ការពិនិត្យលក្ខណៈសម្បត្តិបេក្ខជនដែលត្រូវស្នើសុំគ្រឿងឥស្សរិយយស<br>ការដាក់មន្ត្រីរាជការឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស | សិក្ខាសាលាបណ្ដុះបណ្ដាលជូនដល់ថ្នាក់ដឹកនាំអគ្គនាយកដ្ឋាន នាយកដ្ឋាន និងការិយាល័យ និងថ្នាក់ដឹកនាំមន្ទីរព័ត៌មានរាជធានី-ខេត្ត (៧០នាក់) | ៤ | ១ | ១ | ១ | ១ |
| | | បទដ្ឋានគតិយុត្តពាក់ព័ន្ធរបស់ក្រសួងព័ត៌មាន (លិខិតរដ្ឋបាលផ្ទៃក្នុងក្រសួង) | | ២ | - | ១ | ១ | - |
| **៤.** | **ការលើកកម្ពស់សមត្ថភាពការងារទំនាក់ទំនងសាធារណៈ និងកិច្ចសហប្រតិបត្តិការ** | | | | | | | |
| ១. | ការគ្រប់គ្រងលំហព័ត៌មាន និងសន្តិសុខព័ត៌មាន | ប្រព័ន្ធគ្រប់គ្រងព័ត៌មានប្រកបដោយប្រសិទ្ធភាព គុណភាព និងភាពប្រទាក់ក្រឡា | បបកថាឯកឧត្តមរដ្ឋមន្ត្រីជូនថ្នាក់ដឹកនាំក្រសួង អគ្គនាយកដ្ឋាន និងនាយកដ្ឋាន និងថ្នាក់ដឹកនាំមន្ទីរព័ត៌មានរាជធានី-ខេត្ត (៣០០នាក់) | ២ | ១ | - | ១ | - |
| ២. | បង្កើនសមត្ថភាពគ្រប់គ្រងព័ត៌មាន និងសាធារណមតិមូលដ្ឋាន | អភិវឌ្ឍសមត្ថភាពមន្ត្រីព័ត៌មាន និងសាធារណៈមតិរាជធានី-ខេត្ត | មន្ត្រីព័ត៌មាន (៥រូប) នៃមន្ទីរព័ត៌មានរាជធានី-ខេត្ត | ២ | ១ | - | ១ | - |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ៣. | លើកកម្ពស់ការទូតព័ត៌មាន (ដើម្បីពង្រឹងភាពជាដៃគូក្នុងតំបន់ និងសាកល) | ស្វែងយល់ពីក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការអាស៊ាន និងរចនាសម្ព័ន្ធអនុវត្ត | - អគ្គនាយករងនៃគ្រប់អគ្គនាយកដ្ឋានទទួលបន្ទុកសម្របសម្រួលការងារសហប្រតិបត្តិការអន្តរជាតិ<br>- ថ្នាក់ដឹកនាំ និងមន្ត្រីនៃនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ<br>- ថ្នាក់ដឹកនាំមន្ទីរព័ត៌មានរាជធានី-ខេត្ត (៧០នាក់) | ២ | - | ១ | - | ១ |
| | | ក្របខណ្ឌកិច្ចសហប្រតិបត្តិការមេគង្គ និងទ្វេភាគី | | ២ | - | ១ | - | ១ |
| | | ក្របខណ្ឌអង្គការសហប្រជាជាតិ និងសហគមន៍អឺរ៉ុប | | ២ | - | ១ | - | ១ |
| ៤. | ការគ្រប់គ្រងសណ្តាប់ធ្នាប់នៃកិច្ចប្រជុំ និងព្រឹត្តិការណ៍ | - ការងារពិធីការជាតិនិងពិធីការការទូត<br>- បដិសណ្ឋារកិច្ច និង<br>- ការកាន់កម្មវិធី | | ២ | ១ | - | ១ | - |
| ៥. | ការបង្កើនកិច្ចសហប្រតិបត្តិការ និងការគាំទ្រ | ការរៀបចំបែបបទ និងវិធីសាស្ត្រក្នុងការសរសេរសំណើគម្រោង | | ២ | - | ១ | ១ | - |
| **សរុបចំនួនវគ្គ/ឆ្នាំនិងត្រីមាស** | | | | **៧៨** | **២២** | **២០** | **២២** | **១៤** |



# អនុសាសន៍សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

## អតីតនាយករដ្ឋមន្ត្រី និងបច្ចុប្បន្នជាប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

# «ជាតិជាមន្ត្រីល្អ»

១. ជាខ្ញុំបម្រើរាស្ត្រ មិនមែនជាចៅហ្វាយរាស្ត្រ
២. កុំធ្វើជាមន្ត្រីជើង១០ ត្រូវធ្វើជាមន្ត្រីជើង២
៣. កុំធ្វើជាមន្ត្រីគ្រាប់ល្ពៅប្រភេទទី១
៤. កុំធ្វើជាមន្ត្រី ដែលមានជំងឺតួឯក
៥. កុំចាំការងាររត់មករកយើង យើងត្រូវរត់រកការងារ
៦. កុំប្រកាន់ឥរិយាបថជាន់ជាង កាប់មែក
៧. កុំប្រមាថ កុំឆ្លាយ កុំបណ្តោយ កុំបំពាន កុំបាត់ម្ចាស់ការ
៨. ដាក់ខ្លួនឱ្យទាប ឬកពារឱ្យសុភាព មាយាទឱ្យខ្ពស់ កុំបាត់ម្ចាស់ការ
៩. ប្រកាន់ខ្ជាប់នូវលក្ខណៈសម្បត្តិ៤យ៉ាង៖ វប្បធម៌សេវាសាធារណៈ ឆន្ទៈម្ចាស់ការ ភក្តីភាព និងមនសិការវិជ្ជាជីវៈ
១០. អនុវត្តគោលការណ៍ ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល និងព្យាបាល
១១. កុំធ្វើជា «មន្ត្រីធូរប្រើង តឹងប្រាស់»

* * * * * * * *